[illegible]

370.1

...ឋ.29

ចរិយាសាស្ត្រ

# អារម្ភកថា

សូមឲ្យ...

នជាតិយេ... នសេចក្ដីយល់ឃើញថា ការទូន្មានខ្លួនរបស់មនុស្ស
...ចំមួយយ៉ាងសំខាន់ក្នុងការសិក្សារបស់សិស្ស ព្រោះការ
...ទខ្លួននេះចាត់ជាចរិយាសិក្សាមួយក្នុងសិក្សាទាំង៤ យ៉ាងមានវិទ្យា
ក្សាជាដើម ។ ទើបខ្ញុំខំប្រឹងប្រែងតែងសៀវភៅដំបូន្មាននេះឡើងឲ្យ
ឈ្មោះថា "ចរិយាសាស្ត្រ" ជាក្បួនសំដែងអំពីចរិយា គឺច្បាប់សម្រាប់
ន្មានខ្លួន ធ្វើមនុស្សឲ្យមានចរិយាសណ្ដាប់ធ្នាប់ល្អ, ឲ្យមានសីលធម៌
ថ្លៃថ្លា វៀរចាកការប្រព្រឹត្តអាក្រក់ទាំងត្រង់ឆ្គងបួលដំនុំចំណោមមិនត្រូវនាទីង
ត្រូវធ្វើខ្លួនឲ្យថោកទាប មិនឲ្យឡើងទៅកាន់ឧត្តមភាពបាន ជា ញឲ្យ
មនុស្សឲ្យខ្ពង់ខ្ពស់សមរម្យទៅតាមភាពរបស់មនុស្សពិតៗ ។ ដ្បិតថា
ស្សយើងដែលបានអត្តភាពមកជាមនុស្សក្រៃសែនក្រ; បានមក
មនុស្សហើយបានរៀនចេះដឹងរាប់ថាជាមនុស្សសំខាន់ពិតមែន, តែ
ចរិយាសណ្ដាប់ធ្នាប់មិនល្អ គ្មានសីលធម៌ល្អមកជួយគាំពារផងទេ
ង់កែខ្លួនឲ្យទៅជាមនុស្សមានលក្ខណៈល្អពុំបានឡើយ ។ ប្រៀប
ផ្ទះដែលសង់ហើយខ្វះគ្រឿងតុបតែង មានតុតាំងម្ជុលកន្ទេល

តែជាដើម ក៏ឃើញថាមិនទាន់គ្រប់គ្រា...
បានស្រួល ទាំងមិនជាទីគាប់ចិត្តក្នុងអ្នកផងដែ...
គេហារមាត់សរសើរពុំទាន់បាន ព្រោះមានតែតួផ្ទះទទេ ដូចច...
ដែលមានតែពង់កាយទទេ, ជារូបគាគ្រាតគ្រាំង ព្រោះខ្វះប...
និងសីលធម៌ ។

សៀវភៅនេះតែងឡើងសម្រាប់គ្រូនិងសិស្សគ្រប់ថ្នាក់ ...
...ាន់ ៗ សូមលោកអ្នកជាគ្រូនិងសិស្សទាំងឡាយ ជ្រើសរើស...
...ប្រតិបត្តិការតាមជំពូកតាមវគ្គ ឲ្យសមទៅតាមថ្នាក់រៀន ។

ខ្ញុំសង្ឃឹមថាសៀវភៅនេះ នឹងបានជាទីគាប់ចិត្តដល់អស់លោ...
ជាគ្រូ និងពួកសិស្សទាំងឡាយមិនខាន គ្រាន់ជាជំនួយក្នុង
បង្ហាត់បង្រៀននិងការសិក្សាផ្ទាល់ខ្លួនផង ព្រោះសៀវភៅចរិ...
សាស្ត្រនេះពុំទាន់មានតែងឲ្យពិស្តារនៅឡើយ ជាហេតុនាំឲ្យ
លំបាកនឹងជ្រើសរើសយកមកប្រើការក្នុងការបង្រៀន ទាំងជាកា...
ឲ្យសិស្សទាំងឡាយបានចេះដឹងខាងចរិយានិងភាសាជាតិ ដើ...
ហ្វាត់ចត់ផង ។

សូមឲ្យក ខាង តាមលំដាប់ហូរហែ លំនាំផែនទីដួចគ្នាតែ
នជាតិយេ

មេរៀនដែលចែកចេញទៅជាវគ្គច្រើនប្តិចទៅតាមផ្ន
រៀននោះ វគ្គទី ១ និយាយពីគោលសំខាន់ៗសម្រាប់ឲ្យសិស្ស
ចងចាំ, បន្ទាប់ នះតែងជាការមាន ប្លុកមេសូត្រដែលសិងសុទ្ធតែ
ជាគ្រឿងប្រដាប់ខ្ទួនា នាំឲ្យអស់សិស្ស អប់រំផ្លូវបញ្ញា ។

២– មេរៀនទាំងឡាយច្រើនដែលដកចេញពីភាសិតចិត្តានិង
វត្តសាស្ត្រខ្លះមកប្រ តប្រកបជាមួយផង ដែលនឹងត្រូវទាទូញឲ្យ
មាតដុកធ្វើជាការហាត់សរសេរផ្ទង់ ឬមេគំនិតកង់ការតែងសេចក្តី
ងការដាក់ឲ្យធ្វើ ។

៣– នៅទីបំផុតជំពូកទីមួយៗមានបញ្ហាចោទសម្រាប់ដាក់ឲ្យ
សិស្សធ្វើ ។

រៀនការនិងភាសិតដែលដក ចេញពីសៀវភៅផ្សេងៗ មាន
ពង់ ស្រ្តីក និងគម្ពីរព្រះពុទ្ធសាសនាជាដើម ដែលអ្នកប្រាជ្ញបុ.
នៗ តែងដុកយកជាគ្រឿងប្រដាប់ការបង្ហាត់បង្ហាញ ទាំងជា

សតិនិងបញ្ញារបស់អ្នកសិក្សាគ្រប់ថ្នាក់គ្រប់ជាន់ ។

ការសិក្សាខាងបរិយាសាស្ត្រនេះ ពប់ថាជា [illegible] មុខការនោះ [illegible] សិក្សាមួយ, មិនមែនជាការបន្ថែមទៅលើការរ [illegible] តាមពិតទៅក៏ជាការនាំឲ្យកើតសតិនិងបញ្ញាអ្នករៀ[ន] [illegible] ផងជាប្រយោជន៍ យ៉ាងសំខាន់ដល់កុលបុត្រទាំងឡាយ ដែលនឹងធ្វើខ្លួនឲ្យទៅជាពល រដ្ឋយ៉ាងថ្លៃថ្នូរ ដែលជាកម្លាំងរបស់ប្រទេសជាតិ មាតុភូមិ ។

អស់លោកអ្នកដែលបានអានរៀនសូត្រ [illegible] សៀវភៅនេះសឹង [illegible] រម្យ [illegible] ប្រយោជន៍មិនត្រឹមតែធ្វើខ្លួនឲ្យមានបរិយាល្អនោះទេ [illegible] អស់ [illegible] ចាំរៀនពាក្យផ្សេងៗ ដែលជាពាក្យប្រដៅសំខាន់ៗ ផង ដឹង [illegible] ប្រទេសក្រុងនិងនាមអ្នកប្រាជ្ញចំណានខ្លះថែមទៀតផង ។

សៀវភៅនេះព្រះគ្រូមុនីសោភ័ណ សេក-នាង សាស្ត្រ [illegible] សាលាបាលីជាន់ខ្ពស់ [illegible] ចារ្យរបស់ខ្ញុំនិងលោក [illegible] បានហៅសាលា [illegible] ក្រុង ភ្នំពេញ [illegible] ពិនិត្យផ្ទៀង [illegible] សម្រួលផង ។

ក្រិយាសព្ទ

370.1
ឧតាញ



សូមឲ្យការសិក្សាដល់អ្នកដែលបានគាន់បានរៀនល្អគលាស
...នជាតិយេស្យាកាត ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

នៅថ្ងៃទី ២០ ខែតុលា ២៤៩៦/១៩៥៣

ភិក្ខុមាស-រឿង (ធម្មធីរោ)

ទំព័រ


រៀនទី១៧ អំពីគ្រូនឹងសិស្ស Les maîtres et les élèves . . . . . ៦៦

រៀនទី១៨ កិច្ចធុរៈផ្ទាល់ខ្លួនរបស់សិស្ស Devoirs personnels de l'écolier

ងារ-សេចក្ដីព្យាយាម-ការស្ដាប់បង្គាប់ដោយគោរព

avail, assiduité., docilité . . . . . . . . . . . . . . ៧១

ភាសិត- ខ្ញុំល) . . . . . . . . . . . . . . . . . . . . . ៧៦

ការអាន (រៀនសត្វក្អែកដឹងគុណទៅមកចំពោះមិត្តសំឡាញ់

. . . . . . . ៧៧

មេរៀនទី ២ ចរិយាសិក្សាជាការចាំបាច់ Nécessité . . . . .

មេរៀនទី៣ គោលរបស់ជីវិត- ករណីយកិច្ច But de la vie - Le devoir. ១៤

ភាសិត - ចិន្ដា - រឿងរ៉ាវ . . . . . . . . . . . . . . . . . . . ១៦

មេរៀនទី ៤ គុណសម្បត្តិ La vertu . . . . . . . . . . . . . ១៧

ភាសិត - ចិន្ដា - រឿងរ៉ាវ . . . . . . . . . . . . . . . . . . . ១៩

ការអាន (កំហុសក្មួចតាបជាំងឡាយ) . . . . . . . . . . . . ២០

មេរៀនទី ៥ អំពីសាសនា និងសាសនិកជន Devoirs envers Dieu . ២៣

មេរៀនទី ៦ សេរីភាព សមភាព Liberté égalité . . . . . ២៤

ការបញ្ជាក់ឡើងវិញ ការដាក់ឲ្យធ្វើ Devoirs écrits. . . . . . . ២៦

ជំពូក ២ CHAPITRE 2

មេរៀនទី៧ ការរស់នៅរបស់គ្រួសារ La vie de famille . . . . ២៩

ភាសិត-ចិន្ដា . . . . . . . . . . . . . . . . . . . . . . . . ៣១

. . . . . . . .

... ប្រព្រឹត្តចំពោះជីដូនជីតានិងចាស់ទុំ ញាតិជិតខាង

Devoirs envers les grands parents. . . . . . . . . . .

មេរៀនទី១៦ ការប្រព្រឹត្តចំពោះបងប្អូនប្រុស-ស្រី Devoirs réciproques

freres et des sœurs. . . . . . . . . . . . . . . . . . .

មេរៀនទី១៧ ការប្រព្រឹត្តនឹងមិត្តសំឡាញ់ Devcirs envers les amis

ភាសិត-មិត្ត . . . . . . . . . . . . . . . . . . .

មេរៀនទី១៨ ការប្រព្រឹត្តទៅវិញទៅមករវាងចៅហ្វាយនាយនឹងខ្ញុំកំដរ

Devoirs réciproques des maitres et serviteurs . . . . . . .

មេរៀនទី ១៩ សង្គហវត្ថុ ការបញ្ជាក់ឡើងវិញ . . . . . . .

## ជំពូក ៣ CHAPITRE 3

មេរៀនទី ១០ សាលារៀន L'école.

គ្រូនិងសិស្ស Les maîtres et les élèves . . . . . . . . . .

ទំព័រ

រៀនទី១៧ អំពីគ្រូនឹងសិស្ស Les maîtres et les élèves . . . . ៦៦

រៀនទី១៨ កិច្ចធុរៈផ្ទាល់ខ្លួនរបស់សិស្ស Devoirs personnels de l'écolier

ងារ-សេចក្តីព្យាយាម-ការស្តាប់បង្គាប់ដោយគោរព

avail, assiduité., docilité . . . . . . . . . . . . ៧១

អាន (សេចក្តីខ្ជិល) . . . . . . . . . . . . . . . . . . ៧៦

រៀនទី១៩ ករណីយកិច្ចទៅវិញទៅមកចំពោះមិត្រសំឡាញ់

evoirs réciproques des camarades . . . . . . . . . . . ៧៧

មេរៀនទី២០ ការចេញពីសាលា Après l'école . . . . . . . . ៨០

កសិត-ចិត្ត . . . . . . . . . . . . . . . . . . . . ៨២

ធើហាត់មើល (លាពីសាលា) Adieu à l'école . . . . . . . ៨៣

ពន្យល់ពាក្យ ការបញ្ជាក់ឡើងវិញ ការដាក់ឲ្យធ្វើ . . . . . . . . . ៨៥

ជំពូក ៤ CHAPITRE 4

មេរៀនទី២១ សុចរិត ទៀងត្រង់ កុហក ពុតត្បុត Sincérité, mensonge,

Hypocricie . . . . . . . . . . . . . . . . . . ៨៩

ភាសិត ចិត្ត . . . . . . . . . . . . . . . . . . . ៩២

រៀនទន្ទេញនឹងខ្លួនចាស់ . . . . . . . . . . . . . . . ៩៣

ពន្យល់ពាក្យ ការអាន (កាប៉ិតរបស់ជ័យ) . . . . . . . . . ៩៥

ពន្យល់ពាក្យ . . . . . . . . . . . . . . . . . . . ៩៦

ការអាន (តាមសកុហក) . . . . . . . . . . . . . . . ៩៧

ទំព័រ

ពន្យល់ពាក្យ . . . . . . . . . . . . . . . . . ៩៨

ការអាន មេស្ត្រី គម្រាធោកដោយស្រីរងរឿងបញ្ហារ . . . . . . ៩៩

ពន្យល់ពាក្យ . . . . . . . . . . . . . . . . . ១០១

មេរៀនទី ២២ សុភាព ព្រហើន អួតអាង

Modestie-Orgueil-Vanité . . . . . . . . . . . . . ១០២

ការអាន (រឿងសត្វកណ្ដុរពីររូប) . . . . . . . . . . . ១០៤

មេរៀនទី ២៣ សេចក្ដីក្លាហានមានប៉ុន្មានយ៉ាង Le courage Ses différentes formes . . . . . . . . . . . . . . . . . ១០៨

ការអាន (សុធនកុមារជាគំរូក្នុងការក្លាហាន) . . . . . . . . . ១១១

មេរៀនទី ២៤ សេចក្ដីខ្នះខ្នែង, ព្យាយាម Energie et persévérance ១១៤

មេរៀនទី ២៥ ខន្តី កំហឹង Patience et colère . . . . . . ១១៧

ភាសិត ចិន្តា មេស្ត្រ (ឃ្មុំនិងរុយ) . . . . . . . . . . . ១២០

ពន្យល់ពាក្យ . . . . . . . . . . . . . . . . . ១២២

ការអាន (ទឹងទាគ) . . . . . . . . . . . . . . ១២៣

ការអាន (ការក្រោធនាំឲ្យខាត) . . . . . . . . . . ១២៥

ការអាន (សត្វរាជសីហ៍នឹងកង្កែប) . . . . . . . . . ១២៦

មេរៀនទី ២៦ ការមានលក្ខណៈជាការចាំបាច់

Nécessité d' avoir du caractère . . . . . . . . . . ១២៩

ការអាន (បុគ្គលប្រាជ្ញាលោភ) . . . . . . . . . . . ១៣២

ទំព័រ

ឧស្សូត្រ ពន្យល់ពាក្យ . . . . . . . . . . . . ១៣៣
ការអាន (មនុស្សលោភប្រឹនខាតដើមទៅវិញ) . . . . . . . ១៣៤
មេរៀនទី ២៧ បរិសុទ្ធិ La pureté . . . . . . . . ១៣៩
មេរៀនទី២៨ អនាម័យ សំអាត ការហាត់ប្រាណ
Hygiène Propreté Gymnastique . . . . . . . . . . ១៤១
ភាសិត បិត្តា . . . . . . . . . . . . . . . . . ១៤៥
ការអាន (ប្អូនស្រីខ្លាញ់ទឹក) . . . . . . . . . . . . . ១៤៦
មេរៀនទី ២៩ ការសន្តោសនឹងការដឹងប្រមាណក្នុងភោជន
Sobriété et tempérance. . . . . . . . . . . . . . ១៤៨
ភាសិត បិត្តា . . . . . . . . . . . . . . . . ១៥០
ការអាន (ល្មោភគ្មានសេចក្តីសន្តោស) . . . . . . . . . . ១៥១
មេរៀនទី ៣០ ជម្ងឺស្រាអាភៀន . . . . . . . . . . . . ១៥២

## ជំពូក ៥ CHAPITRE 5

មេរៀនទី ៣១ ទ្រព្យខាងក្រៅ Les biens extérieurs . . . ១៥៨
ការងារ Le travail . . . . . . . . . . . . . . . . "
ការគោរពទ្រព្យ . . . . . . . . . . . . . . ១៦១
ត្រូវស្រឡាញ់ការងារ . . . . . . . . . . . . . ១៦២
មេរៀនទី ៣២ សម្រាក សប្តាហៈ Le repos hebdomadaire . . . ១៦៥

មេរៀនទី ៣៣ របៀប L'ordre . . . . . . . . . . . . . . ១៦៦
ភាសិត - ចិន្តា . . . . . . . . . . . . . . . . . . . . . . ១៦៧
មេរៀនទី ៣៤ សំចៃ សន្សំទុកបំណុលការ បំណុល •
Economie-Epargne-Dettes . . . . . . . . . . . . . . ១៦៨
មេត្រូ (សត្វរែនឹងស្រមោច) . . . . . . . . . . . . ១៧០
ពន្យល់ពាក្យ . . . . . . . . . . . . . . . . . . . . . ១៧១
មេរៀនទី ៣៥ កំណាញ់ ខ្ជះខ្ជាយ ល្បែងស៊ីសង
Avarice - Prodigalité - jeu . . . . . . . . . . . . ១៧៣
ការអាន (រឿងកំណាញ់ក្រៀតម្រា) . . . . . . . . . . . ១៧៦
ពន្យល់ពាក្យ . . . . . . . . . . . . . . . . . . . . . ១៧៩
មេរៀនទី ៣៦ ករណីយកិច្ចចំពោះសត្វ Devoirs envers les animaux ១៨០
ការអាន (សេចក្ដីស្នេហារបស់សត្វឆ្កែ) . . . . . . . . . . . ១៨៣
ពន្យល់ពាក្យ . . . . . . . . . . . . . . . . . . . . . ១៨៥
ការបញ្ជាក់ឡើងវិញ . . . . . . . . . . . . . . . . . ១៨៧

## ជំពូក ៦ CHAPITRE 6

ករណីយកិច្ចរបស់មនុស្សចំពោះសង្គម Devoirs de l'homme envers la société
ករណីយកិច្ចចំពោះយុត្តិធម៌ Devoirs de justice . . . . . . . . . . ១៩១
មេរៀនទី ៣៧ ការចាំបាច់ នឹងវត្តុធម៌ សម្រាប់ជីវិតរបស់សង្គម

ទំព័រ

Nécessité et avantages de la vie en société . . . . . . . . ១៩១

ភាសិត ចិន្តា . . . . . . . . . . . . . . . . . . . ១៩៣

ការអាន (ភាតរភាព មនុស្សជាតិ) La fraternité humaine . . . ១៩៤

ពន្យល់ពាក្យ . . . . . . . . . . . . . . . . . ១៩៦

មេរៀនទី ៣៨ គោរពជីវិតអ្នកដទៃ Respect de la vie d'autrui . . ១៩៧

ភាសិត ចិន្តា ការបញ្ជាក់ឡើងវិញ . . . . . . . . . . . ១៩៩

មេរៀនទី ៣៩ គោរពចំពោះមនុស្សនិងសត្វ . . . . . . . . ២០០

ការអាន (ជើងជប៉ុន) . . . . . . . . . . . . . . ២០២

មេរៀនទី ៤០ ការគោរព ចំពោះការធ្វើ . . . . . . . . ២០៥

មេរៀនទី ៤១ គោរពសេរីភាពរបស់អ្នកដទៃ . . . . . . . .

Respect de la liberté d'autrui . . . . . . . . . . ២០៦

ភាសិត ចិន្តា ការអាន (សេរីភាពក្នុងទាសភាព) . . . . . . . . ២១០

ពន្យល់ពាក្យ . . . . . . . . . . . . . . . . ២១២

មេរៀនទី ៤២ អធ្យាស្រ័យ-ជំនឿ-មតិ

Tolérance-Croyances-Opinions . . . . . . . . . . . ២១៣

មេរៀនទី៤៣ គោរពកេរ្តិ៍ឈ្មោះអ្នកដទៃ, ក្លាំទោស, និន្ទា

Respect de la réputation d'autrui, calomnie, Médisance . . . ២១៦

ការអាន (អណ្ដាត) . . . . . . . . . . . . . ២១៨

ទំព័រ

មេរៀនទី៤៤ គោរពទ្រព្យជាអចលនវត្ថុរបស់អ្នកដទៃ

Respect des propriétés d' autrui . . . . . . . . ២២១

ការអាន (ទ្រព្យជាអចលនវត្ថុ) . . . . . . . . . . ២២៤

មេរៀនទី៤៥ គោរពសំដីដែលពោលហើយ និងពាក្យសន្យា

Respect de la parole donnée et des contrats . . . . . . ២២៦

មេសូត្រ (សត្វស្រមោចនឹងរៃ) ពន្យល់ពាក្យ . . . . . . . . ២២៨

មេរៀនទី៤៦ ចិត្តសប្បុរស Devoirs de charité

ចិត្តល្អ La bonté . . . . . . . . . . . . . ២៣១

ការអាន (លក្ខណចិត្តល្អ) . . . . . . . . . . . ២៣៣

ការអាន (សត្វលលកនឹងស្រមោច) . . . . . . . . . ២៣៥

មេសូត្រ ពន្យល់ពាក្យ . . . . . . . . . . . . ២៣៦

មេរៀនទី៤៧ យ៉ាងដូចម្តេចដែលហៅថាក្រសួងមហាជន . . . . ២៣៨

មេរៀនទី៤៨ អ្នករួមជាតិចំពោះក្រសួងសំរាប់មហាជនដែលរកផលការកាន់កាប់ ២៣៩

មេរៀនទី៤៩ ការបេះគួរសម

La politesse, la courtoisie, la bonne grâce . . . . . . ២៤២

មេរៀនទី៥០ គំនិតយល់ខុសឬត្រូវ Esprit critique . . . . . . ២៤៩

ការផឹកឡើ . . . . . . . . . . . . . . ២៥២

## ជំពូក ៧ CHAPITRE 7


ករណីយកិច្ចចំពោះប្រទេសជាតិមាតុភូមិ Devoirs envers la patrie

មេរៀនទី៥១ ប្រទេស ស្នេហាជាតិ ទង់ជាតិ

La patrie-Le patriotisme-Le drapeau . . . . . . . . . . . ២៥៦

ភាសិត បិត្ត . . . . . . . . . . . . . . . . . . . . . ២៥៨

មេរៀនទី៥២ តិមាតុភូមិតូចទៅមាតុភូមិធំ Petite patrie et grande patrie ២៦០

មេរៀនទី៥៣ សេចក្តីស្នេហាចំពោះមាតុភូមិ . . . . . . . . ២៦៤

មេរៀនទី៥៤ សេចក្តីស្នេហាពិតប្រាកដ . . . . . . . . . ២៦៥

មេរៀនទី៥៥ កម្ពុជា ឫទ្ធិអំណាច Le Cambodge ses grandeurs . ២៦៨

ការអាន (ម្ចាស់ដែលហៅជាប្រទេស) . . . . . . . . . ២៧១

មេរៀនទី៥៦ គោរពច្បាប់សម្រាប់ប្រទេស Respect des Lois . . ២៧៣

មេរៀនទី៥៧ ករណីយកិច្ចចំពោះលោកនីតិ, ពន្ធដារ, ការការសឹក

Devoris civiqnes-L'impôt-Le service militaire . . . . ; ២៧៧

មេរៀនទី៥៨ ករណីយកិច្ចចំពោះលោកនីតិ, ការបោះឆ្នោត

Devoirs civiques-Le vote . . . . . . . . . . . . . ២៨០

មេរៀនទី៥៩ ស្នេហាជាតិរបស់ស្ត្រីនិងកុមារ Patriotisme des femmes

et des enfants . . . . . . . . . . . . . . . ២៨៥

បទនគររាជជាតិ . . . . . . . . . . . . . . . ២៨៧

## ជំពូក ១

## Chapitre premier

# គោលការណ៍ជាទូរ៉ាល់នៃចរិយាសាស្ត្រ

# ករណីយកិច្ចចំពោះសាសតា

## Principes Généraux de morale
## Devoirs envers Dieu

### មេរៀនទី ១- សតិសម្បជញ្ញៈ

### LA CONSCIENCE

គ្រប់តែអ្នកប្រកាសលទ្ធិសាសនាក្នុងសកលលោក រមែងមានពាក្យប្រៀនប្រដៅដូចនេះគឺ: "កុំឲ្យធ្វើអំពើអាក្រក់(បាប) ឲ្យធ្វើតែអំពើល្អ ឲ្យផុសខាត់ចិត្តឲ្យស្អាតផូរផង់" នេះជាពាក្យប្រៀនប្រដៅរបស់អ្នកប្រាជ្ញទាំងឡាយ ។

ពាក្យទាំង ៣ បទនេះ ត្រូវគ្នានឹងពាក្យប្រៀនប្រដៅអ្នកប្រាជ្ញពុទ្ធសាសនាម្នាក់ក្រោយដែលបានកសាងសន្សំអភិនីហារ អស់កាលដ៏យូរលង់ បានសម្រេចកិច្ចរបស់ខ្លួនគ្រប់យ៉ាងហើយ តែងគ្រប ប្រដៅវេនេយ្យសត្វស៊ើរតែគ្រប់ដំបន់ក្នុងលោក ដែលមានមនុស្ស

ប្រមាណជាជាង៥០០ លាននាក់ជឿកាន់តាម ៗ ពាក្យប្រៀនប្រដៅនេះនៅស្ថិតស្ថេររស់ ២៥៧៧ ឆ្នាំហើយ រហូតមកដល់សព្វថ្ងៃ ៗ អ្នកប្រាជ្ញពុទ្ធសាសនាម្នាក់នេះ បានទទួលនាមពីមនុស្សនិងទេវតា មារព្រហ្ម លើកដំកើងឲ្យឈ្មោះថា "ព្រះពុទ្ធ" ប្រែថា "អ្នកត្រាស់ដឹង" កាលដែលបានត្រាស់ដឹងហើយ បានពោលថា :

"កុំឲ្យធ្វើអំពើអាក្រក់ទាំងពួង, ឲ្យធ្វើតែការណាល្អ, ឲ្យខំដុសខាត់ចិត្តឲ្យស្អាត, នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ" ៗ

រហូតដល់ទ្រង់ទៀបនឹងបរិនិព្វាន ទ្រង់បានផ្ចៀតទូន្មានផ្តាំទៀតថា: "អ្នកទាំងឡាយ ចូរកុំប្រមាទក្នុងសង្ខារទាំងឡាយឡើយ" ៗ

ពាក្យថាកុំប្រមាទឬអប្បមាទនេះ ចេញមកជាពាក្យថាសតិ (១) និងសម្បជញ្ញៈ (២) គឺថាកុំធ្វេសប្រហែស ៗ ចេញទៅជាការគោរព ៗ ចេញទៅជាការសំអាត ៗ ទៅជាការគួរសម ៗល ៗ

---

១- សតិ ប្រែថា ស្មារតី, សេចក្ដីរលឹក ។ ២- សម្បជញ្ញៈ ប្រែថា ការដឹងព្រម, ដឹងខ្លួន ។

ឥឡូវនេះយើងលើកយកពាក្យថា សម្បជញ្ញៈ មកនិយាយជាលំដាប់តទៅ:

អធិប្បាយ- សម្បជញ្ញៈ

វិចារណញ្ញាណ (la raison) ដែលជាសម្បត្តិរបស់មនុស្សអាចនឹងសំដែងចេញមកខាងក្រៅ ជាទ្រង់ទ្រាយ ២ យ៉ាងគឺ ១.វិចារណញ្ញាណនោះ អាចឲ្យយើងស្គាល់សេចក្តីពិតនឹងសេចក្តីមិនពិតដែលជាហេតុនាំឲ្យកើតវិទ្យាសាស្ត្រ (la science) បាន ។ ២.វិចារណញ្ញាណនេះអាចពិចារណានូវអំពើនៃមនុស្សលោកដឹងថា អំពើនេះអាក្រក់ អំពើនោះល្អ, ប្រៀបដូចជាទៅក្រមម្នាក់សម្រាប់កាត់សេចក្តី, បើយើងបានធ្វើអំពើអាក្រក់, នឹងដាក់ទណ្ឌកម្មដល់យើង, បើយើងបានធ្វើអំពើល្អវិញ, ទៅក្រមនោះនឹងឲ្យរង្វាន់ដល់យើងសរសើរឲ្យយើងសប្បាយចិត្ត; វិចារណញ្ញាណដែលសម្រាប់ដឹងនឹងពិចារណាអំពើអាក្រក់ឬល្អរបស់មនុស្សឈ្មោះថា សម្បជញ្ញៈ ប្រែថាសេចក្តីដឹងខ្លួន, សេចក្តីមិនភ្លេចខ្លួន, ត្រូវនឹងពាក្យបារាំងសែសថា (la conscience) ។

យើងអាចដឹងច្បាស់ថា អំពើដែលយើងបានប្រព្រឹត្តហើយ ជួនកាលធ្វើឲ្យខ្លួនយើងមានចេតនាសោមនស្សនឹងខ្លួនយើង ហាក់បីដូចធ្វើខ្លួនយើងឲ្យមានសេចក្ដីថ្លៃថ្នូរជាងមុន, ជួនកាលអំពើនោះធ្វើឲ្យយើងដឹងថា ខ្លួនយើងចុះតម្លៃអន់ថយ ។ បើខ្ញុំបានធ្វើបាបកូនក្មេង ដែលនៅតូចជាងខ្ញុំ ឬបានធ្វើត្រាប់មនុស្សម្នាក់ដើរឆ្អាក់ ឬមួយខ្ញុំបាននិយាយកុហកគ្រូគុនខ្ញុំ លុះខ្ញុំបានប្រព្រឹត្តដូច្នេះហើយ ខ្ញុំមានសេចក្ដីអាក់អន់ស្រពាន់ក្នុងចិត្ត ខ្ញុំដឹងថា ខ្លួនខ្ញុំជាមនុស្សថយថោក, ប៉ុន្តែបើខ្ញុំបានជួយគាំពារមនុស្សដកពិការវិញ, នោះខ្ញុំនឹងសប្បាយចិត្ត ។

សេចក្ដីដែលបណ្ដាលឲ្យខ្ញុំមានចិត្តសោមនស្ស ឬសេចក្ដីអាក់អន់ចិត្តនឹងខ្លួនឯងដូច្នេះហៅថា សម្បជញ្ញៈ ។

សេចក្ដីសង្ខេប :

សម្បជញ្ញៈជាចៅក្រមម្នាក់ត្រឹមត្រូវជាទីបំផុត, ប៉ុន្តែចៅក្រមនេះមិនអាចឲ្យដំបូន្មានជានិច្ចទេ ។ សម្បជញ្ញៈតែងមានសេចក្ដីភ័ន្តច្រឡំ ។ បើដូច្នេះហើយ ត្រូវតែបង្ហាត់ហ្វឹកហ្វឺនសម្បជញ្ញៈឲ្យចេះ

ពិចារណាត្រឹមត្រូវ កុំឲ្យភ័ន្តច្រឡំ ។

សេចក្ដីអធិប្បាយ : សម្បជញ្ញៈរបស់យើងហាក់ដូចជាភ្នែកទិព្វ ហាក់ដូចជាចៅក្រមម្នាក់ដែលមិនទទួលសំណូកសោះ ហើយអាចបំភ្លឺយើងមួយរំពេចពីអំពើទាំងគំនិតរបស់យើងទាំងឡាយ ។ សេចក្ដីពិតថា វិញ្ញាណខាងក្នុងនេះអាចជួយបានដោយសក្ដិសិទ្ធណាស់ ហើយបើឥតអំពីវិញ្ញាណនេះ យើងក៏ពុំអាចដឹងចិត្តគំនិតនៅក្នុងបេះដូងយើងបានឡើយ, ប៉ុន្តែសម្បជញ្ញៈនេះ មិនអាចប្រព្រឹត្តទៅបានពេញលេញជាដរាបទេ ។ មុននឹងធ្វើអំពើនីមួយ ៗ បំណងនិងតណ្ហាផ្សេង ៗ តែងតែចូលមកលុកលុយចេតនារបស់យើង ៗ យើងប្រព្រឹត្តធ្វើអំពើអាក្រក់ហួសទៅហើយ ដោយមានមោហៈមកបាំង លុះប្រព្រឹត្តហើយ ទើបសម្បជញ្ញៈធ្វើឲ្យយើងដឹងថា យើងបានប្រព្រឹត្តធ្វើអំពើខុស ៗ វិប្បដិសារីក៏កើតឡើង គឺថាយើងមានសេចក្ដីក្ដៅក្រហាយក្នុងចិត្ត ។

តើសម្បជញ្ញៈមានភ័ន្តច្រឡំឬទេ? មាន, ព្រោះមោហៈនិងតណ្ហា ។ល។ តែងតែមកបាំងសម្បជញ្ញៈមិនឲ្យមើលឃើញនូវសេចក្ដី

ពិត ៗ មានមនុស្សខ្លះ បានប្រព្រឹត្តអំពើអាក្រក់ហើយមិនមាន វិប្បដិសារី មិនមានសេចក្ដីក្ដៅក្រហាយក្នុងចិត្តដែរ ព្រោះមនុស្សនោះធ្លាប់ប្រព្រឹត្តធ្វើអំពើអាក្រក់នោះជាយូរអង្វែងមកហើយ ដូចជាពួកចោរដែលធ្លាប់សម្លាប់គេញយៗ ចោរនោះអាចប្រព្រឹត្តបទឧក្រិដ្ឋនេះដោយឥតមានស្ដាយក្រោយ ។

មានមនុស្សមួយពួកទៀត តែងតែពិចារណាពីអំពើរបស់ខ្លួនតឹងហួសប្រមាណ មនុស្សនោះរមែងនឹកថា ខ្លួនបានប្រព្រឹត្តបទឧក្រិដ្ឋ, តែការពិត អំពើដែលមនុស្សនោះបានប្រព្រឹត្តមិនមានទម្ងន់ដល់ម្ល៉ោះឡើយ ។

ដូច្នេះយើងឃើញថា សម្បជញ្ញៈរបស់យើង ជួនកាលធូរហួសប្រមាណ ជួនកាលតឹងពេក ពុំអាចមើលឃើញសេចក្ដីពិតឲ្យបានជាក់ច្បាស់ ។ បើយើងចង់ឲ្យសម្បជញ្ញៈរបស់យើងមានភ្នែកភ្លឺច្បាស់ស្គាល់សេចក្ដីពិតនិងសេចក្ដីមិនពិត លុះត្រាតែយើងបានអប់រំហ្វឹកហ្វឺនវិញ្ញាណនេះឲ្យបានភ្លឺច្បាស់ ប្រៀបបីដូចជាពេជ្រមួយគ្រាប់ លុះត្រាតែយើងយកមកច្នៃ ទើបអាចចោលពន្លឺមកខាងក្រៅបាន ។

# ភាសិត-បិត្ដា-រឿងរ៉ាវ

## Proverbes—Pensées—Mot Historique

សេចក្ដីភ្លេចភ្លាំងសតិសម្បជញ្ញៈក្នុងការប្រកបកិច្ច ជាហេតុឲ្យខូចខាតការងារ, សេចក្ដីភ្លេចភ្លាំងក្នុងកិច្ចដែលត្រូវរក្សាសីលការពារ ជាហេតុឲ្យសីលពព្រុសពពាលចិត្តអណ្ដែតអណ្ដូងកាយមាយ ។

ការភ្លេចសតិ ជាហេតុឲ្យរលឹកមិនឃើញ នូវកិច្ចដែលត្រូវគិត-ធ្វើ-និយាយ ។

សេចក្ដីមិនប្រមាទ បានដល់ការមិននៅប្រាសចាកសតិគ្រប់ឥរិយាបថ មានសម្បជញ្ញៈគឺសេចក្ដីដឹងខ្លួនជួយឧបត្ថម្ភករណីយកិច្ច ដោយសេចក្ដីមិនប្រមាទរមែងសម្រេចផលល្អ ដូចបុគ្គលដែលមានទ្រព្យច្រើនហើយរក្សាទុក ។

អ្នកមិនប្រមាទរមែងមិនសោយសោកក្នុងលោកទាំងពីរ ។

វិជ្ជាគ្មានមនសិការៈ(សតិសម្បជញ្ញៈ) តែងនាំឲ្យអន្តរាយអាត្មា ។

វិទ្យាទុច្ចរិត នាំអ្នកប្រព្រឹត្ត ឲ្យដើរខុសផ្លូវចាកគន្លងធម៌ដ៏ល្អត្រឹមត្រូវ នាំឲ្យអាស្រូវ អន្តរាយអាត្មា ។

ថ្ងៃមួយ គេបានសួរឥសីម្នាក់ថា ដូចម្ដេចដែលហៅថាការរស់នៅដោយគ្មានទុក្ខ? ឥសីនោះឆ្លើយថា គឺការដែលមានសតិសម្បជញ្ញៈ ។ អធិប្បាយថា: ចិត្តរបស់បុគ្គលណាដែលមានសតិសម្បជញ្ញៈគ្រប់គ្រងរក្សាល្អហើយ, ចិត្តរបស់បុគ្គលនោះ តែងជ្រើសរើសរកចំណែកណាដែលល្អ ៗ ប្រៀបដូចជារថដែលទឹមដោយសេះដែលមាននាយសារថីប៉ិនប្រសប់ឈ្លាសវៃទៀងបរទៅតាមផ្លូវហើយ រមែងលឿនត្រង់ទៅតាមផ្លូវ មិនមានទាស់ទ្គង ពាំងមិនមានសេចក្ដីអន្តរាយដល់ជនណាមួយឡើយ រមែងញ៉ាំងប្រយោជន៍ឲ្យសម្រេចក៏ដូច្នោះដែរ ។

"ថ្ងៃចាំងអស់បញ្ឆាក់ឲ្យយើងដឹងថា មរណៈជិតមកដល់ហើយ"

"កុំប្រមាទខ្លួន ប្រឹងប្រែងថែថួន ត្រង់បុណ្យកុសល រស់គាប់ងាប់គួរ ពេលសង្ខារដល់ កុំឲ្យកន្ទួល កុំឲ្យស្ដាយក្រោយ" ។

សំណួរ.- ដូចម្ដេចបានជាលើកសតិសម្បជញ្ញៈជាធំជាងគេ ?

ចូរទាញឧទាហរណ៍មកប្រៀបធៀប ?

យើងធ្វើការអ្វីៗ ទោះល្អក្ដី អាក្រក់ក្ដី តើសតិសម្បជញ្ញៈនោះរៀបប្រាប់ដូចម្ដេច?

ចូរលើកភាសិតចំណាំខ្លះ ក្នុងសតិសម្បជញ្ញៈ ?

# វិធីអាន

## សតិសម្បជញ្ញៈ

### រឿងសត្វក្អែកនិងខ្មោចដំរី

មានក្អែក ១ បានឃើញខ្មោចដំរី ១ អណ្តែតទឹក ក៏ចុះទំចឹកស៊ី ៗ សាកដំរីអណ្តែតទៅតាមខ្សែទឹកដល់កណ្តាលសាគរ ។ ក្អែកនោះភ្លើតភ្លើនភ្លេចស្មារតី ពុំបានគិតនឹងហើរវិលមកកាន់ទីគោកឡើយ, លុះស៊ីដំរីហើយ នឹងគេចហើរមកទីគោកពុំបាន ព្រោះនៅកណ្តាលមហាសមុទ្រ មើលត្រើយពុំយល់ ។ ក្អែកនោះហើរមកមិនដល់គោក ក៏គាំងស្វាបអស់កំលាំងធ្លាក់លិចចុះក្នុងមហាគង្គាដល់នូវក្តីមរណៈសូន្យជីវិតទៅហោង ។

រឿងនេះបានគតិថា : ការដែលមិនមានសតិសម្បជញ្ញៈតែងតែជួបប្រទះនឹងសេចក្តីសោយសោកក្នុងលោកទាំងពីរគឺលោកនេះនឹងលោកខាងមុខ ដូចសត្វក្អែកដែលភ្លេចខ្លួនដល់ក្តីមរណៈ ។

## ពន្យល់ពាក្យ

ក្អែក ន. ឈ្មោះបក្សីមួយយ៉ាង សម្បុរខ្មៅស្មុគ្គ ដំណើរលោត ៗ

សាគរ ន. សមុទ្រ (មានទឹកប្រៃ)

មហាគង្គា ន. ទន្លេធំ, សមុទ្រ

គាំង កិ. កម្រើកមិនរួច, នៅទឹងថ្កល់ គឺកម្រើកមិនបាន

ត្រើយ ន. ទីគោក, ត្រើយខាងនាយ ត្រើយខាងអាយ

* * *

## មេរៀនទី២- បរិយាសិក្សាជាការចាំបាច់(១)

## Nécessité de la morale

១– កុលបុត្រត្រូវប្រើពេលវេលា ដើម្បីរៀនដើរ រៀននិយាយ រៀនពិចារណា ព្រោះកិរិយាទាំងនេះ ពុំមែនបេះឯង ៗ ភ្លាមៗតែម្តង ដោយឥតសំចៃពេលវេលារៀននោះទេ យ៉ាងណាមិញ, សតិសម្បជញ្ញៈក៏ពុំមែនមកឯង ឲ្យសម្រេចប្រយោជន៍តាមប្រាថ្នា ដោយឥតហាត់រៀនសូត្រក៏យ៉ាងនោះដែរ គឺលុះត្រាតែខំព្យាយាមហ្វឹកហ្វឺនហាត់ពត់ចិត្តមិនធ្វេសប្រហែសក្នុងកិច្ចការទាំងពួង ទើបសតិសម្បជញ្ញៈស្ថិតនៅរឹងប៉ឹងទៅបាន ៗ

១- គឺក្បួនបរិយាត្រូវតែរៀនខានពុំបាន។

សតិសម្បជញ្ញៈជាចៅក្រមឬជាមិត្តភក្តិដ៏ល្អ អាចនឹងជួយបំភ្លឺក្នុងករណីយកិច្ចរបស់យើង ។ ការអប់រំចិត្ត ឬចរិយា តែងបានមកពីការបង្ហាត់បង្រៀនរបស់គ្រួសារវង្សត្រកូលនៃមាតាបិតាជាដំបូង; លុះតមកទៀតបានមកពីការសិក្សាក្នុងសំណាក់គ្រូនៅទីសាលា ពីមិត្តភក្តិ ពីការសិក្សាទូសាសនា និងមកពីការចេះត្រិះរិះខ្លួនឯងផ្សំថែមទៀតផង ។ សតិសម្បជញ្ញៈគេតែងផ្គត់ផ្គង់ថែរក្សាឃុំគ្រងឲ្យមានក្នុងខ្លួនរហូតអស់ជីវិត មិនត្រូវធ្វេសប្រហែសឡើយ ដ្បិតយើងច្រើនភ្លេចគោលការណ៍របស់ចរិយាសំខាន់ៗ ដែលយើងបានអប់រំមក ។

២–ចរិយាសាស្ត្រនេះ ជាវិទ្យាសាស្ត្រក្បួនចំណេះមួយយ៉ាងសំខាន់ គេរាប់អានទុកដូចជាថ្នាំឧសថនិងក្បួនអនាម័យ ដ្បិតជាគ្រឿងរក្សាខ្លួន គេត្រូវការរាប់អានឲ្យណាស់ ដូចចរិយាសាស្ត្រដែលបង្ហាត់យើងឲ្យថែទាំរក្សាចិត្តឲ្យបានសុខសាន្ត ។

ចរិយាសាស្ត្រនេះ អាចបំភ្លឺយើងក្នុងកិច្ចការរបស់យើងចំពោះសាស្តា ចំពោះមនុស្សដូចគ្នា និងចំពោះខ្លួនយើង ព្រមទាំងធ្វើ

ឲ្យយើងទៅជាមនុស្សសុចរិតស្លូតត្រង់ត្រឹមត្រូវល្អ ជាទីរាប់អានស្រឡាញ់នៃជនទាំងពួង ។

ចរិយាសាស្ត្រនេះ ជាវិទ្យាសាស្ត្រក្នុងការប្រតិបត្តិទំនៀមទម្លាប់ ដែលជាប្រពៃណី ប៉ុន្តែការប្រតិបត្តិនេះ មិនសុទ្ធតែត្រឹមត្រូវទៅតាមប្រពៃណីប៉ុណ្ណោះទេ ។

៣ – សិក្ខាបទទាំងឡាយក្នុងចរិយាសាស្ត្រ ជាការរុងរឿងថ្លៃថ្នូររបស់មនុស្ស ។ បណ្ដាសត្វមានវិញ្ញាណទាំងប៉ុន្មាន ដែលអាស្រ័យនៅលើផែនដី មានតែមនុស្សមួយពួកទេ ដែលអាចទទួលខុសត្រូវចំពោះកម្មរបស់ខ្លួន គឺចំពោះអំពើដែលខ្លួនត្រូវធ្វើនោះ ដ្បិតជាមនុស្សមានវិចារណញ្ញាណនិងសេរីភាព ។

អធិប្បាយថា : គ្មានអ្វីនឹងមកពាំងមនុស្សមិនឲ្យសម្រេចតាមគំនិតបំណងរបស់ខ្លួននោះទេ ។ ចំណែកខាងសត្វមានខ្លះក៏មានការចេះដឹងខ្លះដែរ គឺចេះជុំកូន សោយទុក្ខវេទនា ដូចជាមនុស្សដែរ តែខ្លះធម្មសញ្ញា គឺថាមិនដឹងជាចំណែកណាល្អ ណាអាក្រក់នោះទេ វាគោរពសភាវគតិ (instinet) តែវាមិនមានការទទួលខុសត្រូវនូវអំពើ

របស់វាបានទេ ។ ឃើញថាសត្វនឹងមនុស្សខុសគ្នាឆ្ងាយណាស់ ។

៤–ការសិក្សាខាងចរិយាសាស្ត្រជាភាគមានប្រយោជន៍ធំបំផុតក្នុងការបង្ហាត់បង្រៀនរបស់យើង, ដូច្នេះគួរតែស្អិតស្អាងសន្សំគំនិតឲ្យបានភ្លឺត្រចះរាល់ថ្ងៃ ដើម្បីនឹងបានបំពេញភារកិច្ចរបស់យើងឲ្យបានពេញលេញ ។

មុខគួរឲ្យឆ្ងល់ថា ចុះតាំងបាច់សិក្សាឲ្យចេះដឹងនូវសិក្ខាបទនៃចរិយាសាស្ត្រធ្វើអ្វី បើយើងមិនត្រូវការឲ្យទៅជាអ្នកចេតឆាយប្រសើរណាស់ណាទេ រៀនតែវិជ្ជាឯទៀតទៅក៏បានល្មមហើយ ?

ឆ្លើយថា យើងមិនត្រូវប្រព្រឹត្តឲ្យដូចជាមនុស្សពាលជាមនុស្សថយថោក មិនស្គាល់ខុសត្រូវនឹងសេចក្តីថ្លៃថ្នូរ ដោយការលះបង់សីលធម៌ បែរជាទៅប្រព្រឹត្តខាងការកំហែងកំហល់ ការឃោរឃៅ កំហឹង ល្មោភ ការខ្ជិល ធ្វើខ្លួនឲ្យធ្លាក់ទៅក្នុងភាពជាសត្វតិរច្ឆាន បាត់ភាពជាមនុស្សទេ ។ យើងត្រូវដឹងថា បណ្តាសព្វសត្តនិករក្នុងលោកនេះមានតែមនុស្សទេដែលអាចដែងទៅថ្នាក់ទី ១ ។

ដូច្នេះមនុស្សត្រូវជាអ្នកមានសីលធម៌និងចរិយាល្អ សមនឹងពាក្យ

សុភាសិតបុរាណថា ៖

“មនុស្សដែលល្អ ៗ ដោយចរិយាល្អ, ល្អដោយសីលធម៌ល្អ, មិនមែនល្អដោយគ្រឿងសំលៀកបំពាក់ គ្រឿងមាសពេជ្រតែងខ្លួននោះទេ” ។

ចោទសួរ.- ក្មេងត្រូវធ្វើដូចម្តេចទើបបានគំនិតរបស់ខ្លួនភ្លឺត្រចះឡើងទៅបាន ?

ការរៀនចរិយាសាស្ត្រ តើត្រូវចាប់រៀនពីអ្វីទៅជាមុន ហើយតទៅអ្វីទៀត?

ហេតុដូចម្តេចបានជាត្រូវហាត់រៀនសតិសម្បជញ្ញៈឲ្យស្ទាត់ជាងរៀនក្បួនពេទ្យអានាម័យទៅទៀត ?

មនុស្សដែលមានសេចក្តីថ្លៃថ្នូរ មកពីអ្វី ?

សត្វមានសេរីភាព និងការទទួលខុសត្រូវចំពោះអំពើរបស់វាដែរឬ ?

មានប្រយោជន៍អ្វីខ្លះពីការរៀនចរិយាសាស្ត្រ ?

* * *

## មេរៀនទី ៣ - គោលរបស់ជីវិត_ករណីយកិច្ច

## Le but de la vie-Le devoir

១– ចរិយាសិក្សានឹងសតិសម្បជញ្ញៈ បង្ហាញឲ្យឃើញថា ជា

គោលរបស់ជីវិត ពុំមែនសំដៅទៅរកសេចក្តីសប្បាយនោះទេ,

មែនពិត សេចក្តីសប្បាយមិនមែនហាមឃាត់ទេ មានអនុញ្ញាតឲ្យ

ច្រើនប្រការដែរ, តែបើគិតតែខាងផ្លូវសប្បាយពេកទៅ ក៏នឹងធ្លាក់ចុះទៅក្នុងថ្នាក់ពួកសត្វតិរច្ឆានដែលថោកទាប ។

អធិប្បាយថា: សេចក្ដីសប្បាយពុំមែនជួយមនុស្សឲ្យឡើងកាន់ឋានៈខ្ពស់នោះទេ, ជាគ្រឿងនាំចិត្តនិងបញ្ញារបស់មនុស្សឲ្យថោកថយខ្សោយចុះទៅវិញ ។ ដូច្នេះសេចក្ដីសប្បាយត្រេកត្រអាលពុំមែនជាគោលរបស់ជីវិតទេ, ព្រោះថាមនុស្សលោកកើតមកតែងជួបប្រទះនឹងសេចក្ដីសុខ-ទុក្ខ, តែសេចក្ដីទុក្ខមានចំនួនច្រើនលើសលប់ជាងសេចក្ដីសប្បាយ ។ ដូច្នេះគេតះតិះដៀលដល់មនុស្សណាដែលកើតមកហើយគិតតែសេចក្ដីសប្បាយ ។ សេចក្ដីទុក្ខនាំឲ្យមនុស្សរិះគិតធ្វើខ្លួនឲ្យបានល្អ ។

២- ករណីយកិច្ចគឺកិច្ចដែលត្រូវតែធ្វើ ។ អំពើល្អរបស់មនុស្សសុចរិត ក៏ដូចជាអំពើល្អរបស់យើងដែរ, ដូច្នេះយើងត្រូវតែចំប្រឹងប្រែងបំពេញករណីយកិច្ចរបស់យើងឲ្យពេញទំហឹង ។

អធិប្បាយថា : យើងស្រឡាញ់ករណីយកិច្ច ពុំមែនតែដោយសារវិចារណញ្ញាណរបស់យើងបង្គាប់ឲ្យយើងធ្វើនោះទេ, គឺករ-

ណីយកិច្ចរបស់យើងយើងត្រូវតែបំពេញ ព្រោះជាការនាំមកនូវសេចក្ដីស្នេហាកប់រក, ទោះបីកិច្ចការនោះជួនស្រាលលំបាកលំបិនថ្ងៃថោកយ៉ាងណាក្ដី ក៏ត្រូវតែធ្វើ ។ គ្មានអ្វីរុងរឿងជាងករណីយកិច្ចរបស់ខ្លួនទេ ។

## ភាសិត-បិត្ដា-រឿងរ៉ាវ

ការកើតមកជាមនុស្សជាការក្របំផុត, បានកើតមកជាមនុស្សហៅថាមហាលាភធំ ។

ការចិញ្ចឹមជីវិតរបស់មនុស្សជាការក្របំផុត ។

មួយដំហានឃ្លាតពីករណីយកិច្ច អាចនឹងនាំយើងទៅឆ្ងាយ ៗ

គេតែងតែសប្បាយនៅវេលាល្ងាច, បើក្នុងវេលាថ្ងៃគេបានបំពេញករណីយកិច្ចរបស់គេ ។

មានរឿងដំណាលថា សេនាបតីម្នាក់ឈ្មោះទុកញ៉ាសៅ បានល្បងសាកបញ្ញប់តំណាងរាស្ដ្រឈ្មោះទុកញ៉ាមៅកុំឲ្យនិយាយការបាន ៗ ទុកញ៉ាសៅលុះបានជួបនឹងគ្រូលោក ក៏ជំរាបគ្រូលោកថា: ការបង្វែរព្រះអាទិត្យឲ្យដើរខុសផ្លូវធម្មតា ជាការងាយជាងបញ្ឈប់

ឧកញ៉ាមៅពីកិច្ចនិយាយរបស់លោក ។

ចោទសួរ.- ការស្វែងរកសេចក្ដីសប្បាយ និងលើកយកជាគោលសំខាន់ របស់ជីវិត បានឬទេ ? សេចក្ដីសប្បាយ ទុកថាជាការអប់រំដ៏ល្អរបស់មនុស្សបានឬទេ ? មនុស្សដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ហៅថាមនុស្សអ្វី ? មនុស្សបែបនេះគួរគេសរសើរឬទេ ? តើយើងសរសើរមនុស្សដូចម្ដេចវិញ ? ដូចម្ដេចទើបហៅថាជាគោលសំខាន់របស់ជីវិត ? ចូរទាញភាសិត-បិន្ទាខ្លះ ពីការរស់នៅនឹងករណីយកិច្ច របស់មនុស្ស ។

*   *   *   *

## មេរៀនទី ៤ គុណសម្បត្តិ

## La vertu

១ – ការបេះបំពេញករណីយកិច្ចដោយធម្មតានិងដោយទៀងទាត់នាំឲ្យយើងមានគុណសម្បត្តិ ។ ដើម្បីឲ្យបានគុណសម្បត្តិនោះ ត្រូវហាត់ទម្លាប់ប្រកបការងារល្អជាធម្មតា ។

អធិប្បាយថា : មនុស្សទុច្ចរិត ដូចណាបេះធ្វើអំពើល្អផងដែរ តែនៅតែប្រព្រឹត្តអំពើទុច្ចរិតដដែល ។ គុណសម្បត្តិល្អ រមែងមានដល់មនុស្សដែលធ្លាប់តែប្រព្រឹត្តល្អជាដរាប ។ មនុស្សយើងពុំមែនកើតមកមានគុណសម្បត្តិជាប់មកជាមួយព្រមតែម្ដងនោះទេ ។

គុណសម្បត្តិនេះគេបានមកពីការហាត់ទម្លាប់យ៉ាងម៉ឺងម៉ាត់ គឺព្យាយាមលះបង់បំណង់ផ្សេងៗ និងការខ្ជិលច្រអូស ឬកិច្ចការណាដែលជាការនាំមិនឲ្យបំពេញករណីយកិច្ចរបស់ខ្លួនបាន ។ ទម្លាប់ប្រឹងប្រែងតែងនាំមកនូវសេចក្ដីសប្បាយ និងគុណសម្បត្តិដែលជាប្រធាននៃសេចក្ដីរុងរឿង ។

២– មនុស្សដែលមានគុណវិបត្តិ គឺមនុស្សមិនមានសេចក្ដីក្លាហាន គ្មានការបេះដឹង គ្មានការប្រាកដប្រជា គ្មានកិរិយាត្រឹមត្រូវ ។

អធិប្បាយថា: មនុស្សមានគុណវិបត្តិ គឺមនុស្សលុះដោយលោភៈ ទោសៈ មោហៈ រកបំណងល្អពុំឃើញ ។ ចិត្តរបស់បុគ្គលនោះជាចិត្តព្រហើនថោកទាបរវើរវាយ ពាយឆាយពុំប្រាកដ ។ កុមារដែលមិនព្យាយាមខំប្រឹងបំបាត់អំពើអាក្រក់នេះទេ មុខជានឹងធ្វើអនាគតរបស់ខ្លួនឲ្យអាប់ឱនពុំខាន ។ ទម្លាប់អាក្រក់របស់ខ្លួននឹងរឹងរឹតតែចំរើនឡើងៗ ដល់យូរទៅនឹងនាំឲ្យទៅជាមនុស្សគ្មានថ្លៃថ្នូរនឹងគេ, ដល់ស្លាប់ទៅ ក៏ស្លាប់ឥតសង្ឃឹមទៀត ។

៣– កុមារទាំងឡាយ ចូរអ្នកខំហាត់ទម្លាប់ធ្វើអំពើល្អ តាំង

ពីក្មេងទៅ, កុំឲ្យទម្លាប់អាក្រក់មកជិះជាន់បាន ។

អធិប្បាយថា : មនុស្សយើងតែងមានកិរិយាវិបត្តិខ្លះ, មានការរឹងរូសចចេសមិនស្ដាប់បង្គាប់, ការក្អាំក្អង, ទឹកមុខមិនល្អ ។ល។ តែត្រូវតែយើងឧស្សាហ៍ព្យាយាមរាំងចិត្តយើងជាដរាប ដើម្បីកែខ្លួនយើងឲ្យបានឈ្នះសេចក្ដីអាក្រក់ទាំងនេះបាន, ត្រូវធ្វើខ្លួនយើងឲ្យបានឡើងជាមនុស្សសុចរិតពិតត្រង់ ដើម្បីនឹងបានបំពេញករណីយកិច្ចរបស់យើងដែលត្រូវធ្វើនោះ ។

ចោទសួរ. ដូចម្ដេចហៅថាគុណសម្បត្តិ? មនុស្សយើងកើតមកមានគុណសម្បត្តិតែម្ដងឬ? មនុស្សមានគុណវិបត្តិអនាគតរបស់វានឹងទៅជាដូចម្ដេច? ទម្លាប់អាក្រក់របស់ខ្លួនយូរៗទៅនឹងទៅជាដូចម្ដេច? ត្រូវឧស្សាហ៍ព្យាយាមយ៉ាងណា ទើបឈ្នះសេចក្ដីអាក្រក់បាន?

## ភាសិត_បិត្ដា_រឿងរ៉ាវ

គុណសម្បត្តិជាសេចក្ដីសុខរបស់ចិត្ត ។

បញ្ញានឹងគុណវុឌ្ឍិ ពុំមែនជាវិសេសវិសាលប៉ុន្មានទេ បើខ្វះគុណសម្បត្តិ ។

អរុណដែលរះឡើងព្រឹកព្រហាម ក៏ពុំមានរស្មីភ្លឺជាងគុណសម្បត្តិរបស់ក្មេងជំទង់ម្នាក់ ។

គុណសម្បត្តិតិចតួចទាំងឡាយ មិនបោលពន្លឺភ្លឺត្រចះក៏ពិតមែន តែក្រអូបសាយ គឺជាផ្កាល្អរបស់ចិត្ត ។

សេចក្ដីធ្វេសប្រហែសតូចតាចក្នុងករណីយកិច្ចទាំងពួងអាចនាំទៅរកកំហុសធំបាន ។

មានបុរសជំទង់ម្នាក់សួរប្រស្នានឹងគ្រូខ្លួនថា : ចុះទ្រព្យល្អអ្វីដែលឪពុកគួរទុកឲ្យកូន? គ្រូឆ្លើយថា : មានតែការរៀបរយ នឹងគុណសម្បត្តិ ។

## ការអាន

## កំហុសតូចតាចទាំងឡាយ

ជនមិនត្រូវមើលងាយអស់ទាំងកំហុសតូចតាចទាំងឡាយឡើយ ។ កំហុសតូចនេះជាសត្រូវតូចក៏ពិតមែន, តែដល់យូរៗទៅនឹងបណ្ដាលឲ្យមានសេចក្ដីវិនាសបាន ។ ពុំមែនសត្វដំរីទេដែលបំផ្លាញផលដំណាំនៅទីវាលរបស់អ្នកស្រុកមង្គលបូរី គឺជាសត្វដង្កូវ-កណ្ដូបទេតើ ដែល

បំផ្លាញផលរបរនោះ ដែលកំពុងនៅខ្ចីក្តី កំពុងទុំក្តី ។ ហេតុបន្តិចបន្តួចដែលតែងតែមានជាប់ហូរហែរមកមិនចេះដាច់ ហើយគេធ្វេសប្រហែសស្មានថាមិនជាអ្វី, នោះក៏ជាសឹកសត្រូវមួយយ៉ាងធំដែលដល់ទៅចុងក្រោយការពារពុំឈ្នះ ។ គេត្រូវតែការពារហេតុផ្តាសាយពេមិនបង់ឲ្យខូចដើមទ្រូង ។

ផើងឆ្នាំងដែលមានពណ៌ខ្មៅជាំបន្តិច មិនទាន់ជាអ្វីនៅឡើយ, តែបើអ្នកមិនប្រញាប់ប្រញាល់ទៅបង្ហាញពេទ្យឆ្នាំងទេ, ឆ្នាំងនោះទឹងខូច; បើអ្នកមិនឲ្យពេទ្យផុកឆ្នាំងដែលស្អុយនោះពេលបេញទេ, ឆ្នាំងឯទៀតខាង ៗ នោះ មុខជាទឹងខូចផង់បន្ត ៗ គ្នា, អ្នកទឹងទៅជាមនុស្សគ្រហុបឆ្នាំង ។

ផ្លែឈើរលួយមួយគេទុកក្នុងកញ្ជើរាងមួយយប់ នាំបណ្ដាលឲ្យផ្លែឈើទាំងឡាយឯទៀតក្នុងនោះរលួយទាំងអស់ ។ ភាសិតបុរាណថា "ត្រីមួយត្រក ស្អុយតែមួយ នាំឲ្យស្អុយទាំងអស់" ។ បើអ្នកអត់ឱនទោសបន្តិចបន្តួចរបស់កូនអ្នក បើអ្នកជួយកែពុំបាន ៗ តែទោសតូចតាចដែលនៅលើខ្លួនអ្នកស្រាប់ គោងតែអ្នកកុំបណ្ដោយ

ត្រូវតែបំបាត់ចេញភ្លាម ៗ ប្រែះតូចដែលកើតលើដែក អាចនឹងស៊ីដែកឲ្យខូចបាន ៗ សត្វកណ្ដៀរតូច ៗ អាចនឹងនាំគ្នាបំផ្លាញផ្ទះឲ្យវិនាសបាន ៗ

## ពន្យល់ពាក្យ

កំហុស ន. ការខុស, កិរិយាខុស, គឺការមិនមានសតិសម្បជញ្ញៈ; ក្មេងច្រើនមានកំហុសក្នុងកិច្ចការទាំងពួង ដោយការធ្វេសប្រហែសៗ

សត្វដង្កូវ ន. សត្វល្អិតនៅទីដី លើដើមឈើ ស៊ីស្លឹកឈើ ផ្លែឈើៗ

កណ្ដូប ន. សត្វស្លាបតូច កើតមកពីសត្វដង្កូវ ជាសត្វបំផ្លាញផលដំណាំ ៗ

កណ្ដៀរ ន. ពួកសត្វល្អិតនៅអាស្រ័យក្នុងដី ជាសត្វបំផ្លាញៗ

កញ្ជើ ន. ល្អីសំរាប់ដាក់វត្ថុផ្សេង ៗ មានស្រូវអង្ករជាដើមៗ

ចោទសួរ.. មនុស្សមានប្រាជ្ញានឹងគុណវុឌ្ឍិ តែបើខ្វះគុណសម្បត្តិ រុងរឿងដែរឬ? ត្រូវធ្វេសប្រហែសកំហុសតូចតាចហើយត្រូវតិះដៀលគុណសម្បត្តិឬ? ព្រោះហេតុដូចម្ដេច? ចូរទាញភាសិត-ចិន្តាខ្លះ ពីគុណសម្បត្តិ។

## មេរៀនទី៩ អំពីសាសនានិងសាសនិកជន

## Devoirs envers Dieu

សត្វនិករទូទៅក្នុងសកលលោក ដែលអាស្រ័យនៅលើផែនដី តែងមានការកើតចាស់ដកឈឺចាប់ ជួបសេចក្តីសុខខ្លះ សេចក្តីទុក្ខខ្លះជាអនេកប្បការ រហូតដល់នូវសេចក្តីស្លាប់ជាទីបំផុត ។ បណ្តាសត្វនិករទាំងអស់នេះ មនុស្សដែលមានធម្មសញ្ញាលើសលែងពីសត្វដទៃ បានរិះរកផ្លូវណាដែលសុខ នាំខ្លួនឲ្យចេញចាកទុក្ខ ទើបបានពឹងផ្អែកទៅលើសាសនាដែលខ្លួនកាន់អានថាជាផ្លូវត្រូវ ។

សាសនានេះឯងហើយដែលជាបង្គោលរបស់មនុស្ស ។ មនុស្សតែងពឹងផ្អែកចាប់តោងឲ្យបានដល់នូវទីបំផុតនៃទុក្ខ ពោលគឺសេចក្តីសុខៗ មធ្យោបាយដែលស្វែងរកសេចក្តីសុខបែបនេះ សមនឹងភាសិតអ្នកប្រាជ្ញរបស់ប្រទេសខ្លះពោលថា "ប្រទេសណាគ្មានសាសនា, ប្រទេសនោះទុកដូចជានាវាធំធេងឥតត្រីវិស័យជាមគ្គុទ្ទេសក៍" ។

នៅប្រទេសកម្ពុជាយើង មានព្រះពុទ្ធសាសនាជាប្រមុខ ដែលបណ្តាជនតែងកាន់អានជាប់ជាបវេណីតាំងពីបុរាណរៀងមក ។ ដូច្នេះនឹង

ពោលតែអំពីពុទ្ធសាសនាដែលកុលបុត្រអ្នកកើតនៅក្នុងប្រទេសកម្ពុជាត្រូវសិក្សា ហើយកាន់តាមថា ពុទ្ធសាសនាជាសាសនារបស់ខ្លួន ។

* * * *

## មេរៀនទី ៦ សេរីភាព - សមភាព

## Liberté-Égalité

សេរីភាពគឺធ្វើមនុស្សឲ្យមានសេរីធម៌ស្មើគ្នា, សមភាពគឺធ្វើឲ្យមានមុខស្មើគ្នា ដូចអ្នកប្រាជ្ញខាងពុទ្ធសាសនាសំដែងថា:

១- ធ្វើមនុស្សឲ្យមានសេរីធម៌ស្មើគ្នា ដូចជាទ្រង់សំដែងចំពោះអម្ពដ្ឋមាណពថា: ម្នាលអម្ពដ្ឋមាណព ការធ្វើឲ្យជាក់ច្បាស់នូវគុណសម្បត្តិគឺវិជ្ជាចរណៈ ដែលមិនមានគុណជាតិដទៃលើសលប់បាន រមែងមាន ព្រោះបានលះបង់នូវការជាប់ជំពាក់ ដោយការពោលប្រកាន់ជាតិ (Caste) ផង, លះបង់នូវការជាប់ជំពាក់ដោយការពោលប្រកាន់គោត្រ (Famille) ផង, លះបង់នូវការជាប់ជំពាក់ដោយការពោលប្រកាន់មានះ (Orgueil) ផង, លះបង់នូវការជាប់ជំពាក់ដោយអាវាហៈវិវាហៈផង ។

អធិប្បាយថា: លុះតែមនុស្សយើងមានសេរីធម៌ស្មើគ្នា ទើបមានគុណសម្បត្តិ គឺវិជ្ជានឹងចរណៈ (Le savoir et la vertu) ។

២–អ្នកប្រាជ្ញខាងពុទ្ធសាសនាតែងពោលពាក្យពិតថា "ធ្វើល្អបានផលល្អ, ធ្វើអាក្រក់បានផលអាក្រក់" ។

អធិប្បាយថា: សេចក្ដីល្អនឹងសេចក្ដីអាក្រក់គ្មាននរណាឲ្យអ្នកណាកើត ប្រៀបដូចការបរិភោគអាហារ, ផលគឺការឆ្អែតនៅលើអ្នកស៊ីខ្លួនឯង, អ្នកដទៃនឹងស៊ីជួសគ្នាពុំបាន ។ ម្យ៉ាងទៀតគោលព្រះពុទ្ធសាសនា ដែលសំខាន់បំផុតត្រង់ចង្អុលបង្ហាញប្រាប់កន្លែងដែលមិនចេះស្លាប់ គឺអមតមហានិព្វាន ព្រោះកន្លែងនេះបើបុគ្គលណាខំព្យាយាមឲ្យបានដល់, បុគ្គលនោះមិនចេះស្លាប់ឡើយ ។ ឯលទ្ធិឯទៀតៗ សុទ្ធតែពោលផ្ទុយពីនេះទាំងអស់ថា "មានគេអាចទទួលធ្វើជួសបាន" ដែលជាការមិនពិតទៅតាមផ្លូវវិទ្យាសាស្ត្រសោះនោះទៅវិញ ។

ហេតុនេះពាក្យថា "មិនឲ្យធ្វើអាក្រក់, ឲ្យបំពេញកុសល, ឲ្យជម្រះចិត្តឲ្យស្អាតផូរផង់" ជាហេតុឲ្យបានដល់នូវអមតមហានិព្វាន ។

ពាក្យនេះជាពាក្យពិតមិនចេះស្លាប់, សឹងមានគេកាប់កានថាជាពាក្យសមហេតុសមផលច្រើនណានដាក់គ្រប់តម្បន់ ៗ

ហេតុនេះកុលបុត្រទាំងឡាយដែលជាអ្នកកាន់ព្រះពុទ្ធសាសនារមែងមានភ័ព្វសំណាង ជាអ្នកថៃថ្កូរុងរឿង ក្នុងលោកសន្និវាសនេះ ទឹងបរលោក ៗ

ចោទសួរ.– ដូចម្តេចដែលហៅថា សេរីភាព សមភាព ?

ពុទ្ធសាសនាធ្វើមនុស្សឲ្យមានសេរីភាព សមភាព ដោយលះអ្វីខ្លះ?

លុះតែមានអ្វី ទើបមនុស្សមានគុណសម្បត្តិ?

ដូចម្តេចដែលហៅថាកម្ម-ផល ?

ក្នុងលោកទាំងអស់ អ្នកប្រាជ្ញតែងប្រៀនប្រដៅដូចម្តេចខ្លះ? ហាមឃាត់មិនឲ្យធ្វើអ្វីខ្លះ ?

## ការបញ្ជាក់ឡើងវិញ _ ការដាក់ឲ្យធ្វើ

១– អ្វីហៅថា សតិសម្បជញ្ញៈ?

២– មនុស្សដែលធ្វើការអ្វី ៗ ច្រើនភ្លាត់ភ្លាំងតែមកអំពីខ្វះអ្វីខ្លះ, ដូចមនុស្សដើរភ្លាត់ជើងដួលក្តី?

៣– ចូរពន្យល់ពីសតិសម្បជញ្ញៈល្អ ទុកដូចជា នាយសារថីបរ

រថ, ធម្មតារថបើបណ្តោយឲ្យតែសត្វទឹមអូសទៅតាមអំពើចិត្តវា តើរថមានការខូចខាតដូចម្តេចខ្លះ? តែបើរថមានគេបរ តើដូចម្តេចទៅវិញ?

•

៤– បើអ្នកធ្វើគូកនអ្នកឲ្យមានទណ្ឌកម្មដោយអ្នកទម្លាក់ទោសទៅលើវា តើអ្នកមានចិត្តគិតដូចម្តេចអំពីអំពើអាក្រក់របស់អ្នក?

៥ – ហេតុដូចម្តេចបានជាអ្នកត្រូវរៀនចរិយាសាស្ត្រ?

៦ – ចូរពន្យល់ពីមនុស្ស ដែលបំពេញករណីយកិច្ច របស់ខ្លួនដោយលំបាកព្រោះពុំបានបង្ហាត់ហ្វឹកហ្វឺន សតិសម្បជញ្ញៈ!

៧– ចូរចង្អុលទោសពីកុមារម្នាក់ឈ្មោះសុធនមានអាយុ ១៥ឆ្នាំ បានប្រើប្អូនវាអាយុ ៥ ឆ្នាំ ឲ្យទៅលួចបេះផ្លែដំណាំគេ!

៨– មនុស្សធ្វើអំពើណាមួយល្អក្តី អាក្រក់ក្តី បានទទួលផលយ៉ាងណាខ្លះ ក្នុងបច្ចុប្បន្ននេះក្តី ទៅបរលោកក្តី ?

៩ – ចូរចង្អុលគោល របស់ជីវិតរស់នៅដើម្បីសេចក្តីសប្បាយ ឬដើម្បីបំពេញករណីយកិច្ច!

១០– ឥឡូវយើងដល់រដូវខែធ្នូ (ដេសំប្រ៍) ហើយ មុនការ

ចូលឆ្នាំថ្មីមកដល់ អ្នកបានបំពេញករណីយកិច្ចរបស់អ្នកជាកូនសិស្ស យ៉ាងហ្មត់ចត់ ក្នុងឆ្នាំដែលកន្លងទៅ តើសតិសម្បជញ្ញៈរបស់អ្នកដូចម្តេច ?

១១- គោលរបស់ពុទ្ធសាសនាដូចម្តេចខ្លះ ?

១២ - ហេតុដូចម្តេចបានជាអ្នកចូលចិត្តកាន់ព្រះពុទ្ធសាសនា ? ពុទ្ធសាសនាមានខ្លឹមសារដូចម្តេចខ្លះ?

១៣ - កិច្ចដែលត្រូវធ្វើចំពោះព្រះពុទ្ធសាសនាដូចម្តេចខ្លះ ?

# ជំពូក ២

# chapitre 2

# គ្រួសារ

# La famille

## មេរៀនទី ៧ ការរស់នៅរបស់គ្រួសារ

## La vie de famille



១- គ្រួសារជាធម្មជាតិបូកណាជាន់ចាស់របស់សមាគមទាំងឡាយៗ

ដែលហៅថាគ្រួសារ គឺជាសមាសភាពរបស់មនុស្ស ដែលទាក់ទងគ្នាដោយចំណងឈាមពីឪពុកម្ដាយ ពីកូនចៅ និងញាតិសាលោហិតតៗទៅ របស់វង្សត្រកូល ដូចជាជីដូនជីតា មាមីងបងប្អូនប្រុសស្រី ។ ច្បាប់សម្រាប់ទទួលមត៌ក អាចបើកអំណាចឲ្យរហូតដល់ទៅញាតិ ៧ សន្តាន (នេះសំដៅតាមប្រពៃណីប្រទេសកម្ពុជា) គេតែងថែមទាំងរាប់បញ្ចូលទៅក្នុងគ្រួសារជាមួយផងនូវអស់ទាំងមនុស្សម្នាខ្ញុំកំដរណាដែលបាននៅបំរើរកាលយូរអង្វែង ក្នុងផ្ទះជាមួយដែលជាមនុស្សមានសន្ដានចិត្តស្មោះស្ម័គ្រស្លូតត្រង់ ហើយមានសេចក្ដីស្នេហាចំពោះត្រកូលនោះ ។

២ - គ្មានអ្វីរឹងរឿងជាងគ្រួសារណាមួយដែលមានសមាជិកឬជាបងប្អូនកូនចៅសាមគ្គីព្រមព្រៀងមូលមិត្តគ្នាដោយសេចក្ដីស្នេហានិងសេចក្ដីសង្គ្រោះគ្នាទៅវិញទៅមកនោះទេ, ព្រោះថា មានតែសង្គហវត្ថុនេះឯង ទើបលើកដំកើងវង្សត្រកូលទៅវិញទៅមកបានដែលហៅថា សេចក្ដីថ្លៃថ្នូររបស់វង្សត្រកូល ។

អធិប្បាយថា: ការនៅរួបរួមគ្នា ស្រឡាញ់គ្នាទៅវិញទៅមក

ការស្រឡាញ់គ្នាលើសអំពីស្រឡាញ់ខ្លួន ការទទួលសេចក្តីសុខទុក្ខជាមួយគ្នា ការជួយដោះទុក្ខធុរៈគ្នាក្នុងពេលដែលមានអាសន្ន មានចិត្តសប្បុរសនឹងគ្នា ដូចជាជីវិតមួយ នេះហើយហៅថាការរក្សាគ្រួសារ ។

គ្រួសារនីមួយ ៗ មានគោត្រនាមប្លែកពីគ្នា ។ ខ្មែរយើងគេយកឈ្មោះជីតាឬឪពុកធ្វើជាគោត្រនាមរបស់គ្រួសារ ។

ចោទសួរ.- ដូចម្តេចដែលហៅថាគ្រួសារ ? មនុស្សណាខ្លះដែលត្រូវរាប់បញ្ចូលជាគ្រួសារ ? ជំនិតគ្រួសារដូចម្តេចខ្លះ ? គ្រួសារដែលមានសេចក្តីរាប់រកគ្នាដ៏ស្មោះស្ម័គ្រតើនឹងទៅជាដូចម្តេចទៅ ? ខ្មែរយើងគេត្រូវយកឈ្មោះណាធ្វើជាគោត្តនាម ?

ឲ្យសិស្ស ២_៣ នាក់និយាយសាពីដើមមកវិញ ។

## ភាសិត_បិត្ត

សហភាពក្នុងគ្រួសារ ជាសេចក្តីសប្បាយក្នុងផ្ទះ, ការគោរពកោតក្រែងចំពោះនាមបិតាទុកជាសម្បត្តិរបស់កូនទាំងឡាយ ។

គ្រួសារជាសាលាបណ្តុះគុណធម៌ ។

ការជួបជុំពួកគ្រួសារ ជាសមាគមដ៏ថ្កើងថ្កាន ។

មនុស្សអកតញ្ញូក្នុងគ្រួសារ លុះចូលទៅក្នុងសមាគមឯណា

ក៏នៅជាអកតញ្ញូដូចដែល ។

មនុស្សដែលសប្បាយ គឺជាមនុស្សមានផលព្រេងដែលខ្លួន ធ្វើល្អពីជាតិមុនមកផង ។

ដូច្នេះការចិញ្ចឹមជីវិតរបស់មនុស្សជាការក្រ ។

ការស្លាប់ជាការដូរបតល្ងីង ។

## វិធីអាន

### ផ្លែទំពាំងបាយជូរមួយទង

គ្មានអ្នករៀនជាន់គ្រួសារ ដែលមូលមិត្តព្រមព្រៀងគ្នាដោយ ស្មោះស្ម័គ្រនោះទេ ។

សេចក្ដីដំណាលថា មានស្ត្រីជាមាតាម្នាក់បានឲ្យទំពាំងបាយជូរមួយទងទៅកូនស្រីរបស់ខ្លួន ។ ធីតាដំទង់ បានទទួលនូវផ្លែនោះ ហើយក៏នឹកឃើញថា ផ្លែទំពាំងបាយជូរមួយទងនេះ ជាសេចក្ដីរីករាយដល់បងប្រុសរបស់ខ្លួន ហើយក៏យកទៅឲ្យ ។

បងប្រុសនោះបានទទួលនូវផ្លែនោះហើយ ក៏និយាយថា :

“ឪពុកអញដែលធ្វើការនៅឯណោះ ប្រហែលជាអស់កម្លាំង, ដូច្នេះ ត្រូវអញយកទំពាំងបាយជូរមួយទងដែលជារបស់ត្រជាក់នេះ ទៅជូនគាត់” ។

ចំណែកបិតាដែលបានទទួលទងទំពាំងបាយជូរនេះ ក្រឡេកទៅឃើញប្រពន្ធខ្លួនដែលនៅមិនឆ្ងាយពីទីនោះប៉ុន្មាន, ក៏ម្នីម្នាទៅជិតភរិយាដើម្បីនឹងឲ្យផលានេះ ។

ទងទំពាំងបាយជូរដែលទទួលទៅក្នុងដៃរាល់គ្នា ក៏ត្រឡប់មកនៅលើដៃម្តាយនោះវិញ ។ មាតាក៏មានអំណរសរសើរដល់ព្រះជាម្ចាស់នឹងសហភាពដែលនៅក្នុងសមាជិកនៃគ្រួសាររបស់ខ្លួន ។

## ពន្យល់ពាក្យ

គ្រួសារ ន. ញាតិ, ត្រកូល, វង្សត្រកូល

សហភាព ន. ភាពជាមួយគ្នាឬត្រូវគ្នា

សាលាបណ្តុះគុណធម៌ ន. សាលារៀននាំឲ្យបានសេចក្តីល្អ, សេចក្តីចំរើន, សេចក្តីបរិសុទ្ធិ, ប្រណីត

**អកតញ្ញូ** គុ. មនុស្សមិនដឹងគុណ, មនុស្សអកតញ្ញូ.

**ស្មោះស្ម័គ្រ ឬ ស្ម័គ្រស្មោះ** គុ. ឬ កិ.វិ. ត្រង់អស់ពីចិត្តឥតកិច្ចកលមាយា, ចិត្តស្មោះ; ស្រឡាញ់ស្មោះ.

**ផ្លែទំពាំងបាយជូរ** ន. ផ្លែវល្លិ៍មានសណ្ឋានមូលដូចផ្លែពុទ្រា វេលាទុំមានពណ៌ក្រម៉ៅដាំ គេយកមកស្ងួតធ្វើជាម្ជូរ, ទំពាំងបាយជូរនៅប្រទេសអឺរ៉ុបគេដាំ មានរសជាតិឆ្ងាញ់ផ្អែម គេយកទៅត្រាំបុកធ្វើជាស្រាទំពាំងបាយជូរ

**ផល** ន. ផ្លែឈើផ្សេងៗ, ផលានុផល.

## ភាសិត-បិត្ដា

ត្រូវដុះលាងសំលៀកបំពាក់ដែលប្រឡាក់ក្នុងគ្រួសារ :

" ការឈ្លោះប្រកែក គ្រួសារបាក់បែក ដោយខ្វែកពីគ្នា
សាច់ញាតិសន្ដាន បែកសាមគ្គា ត្រូវតែផ្សះផ្សា ដោយស្ងាត់កំបាំង"

ឪពុកយ៉ាងណា កូនយ៉ាងនោះ :

"សន្ដានបិតា អាក្រក់ល្អជា កូនតែងតែធ្វើ ទៅតាមលំអាន

ដូចគល់ផ្លែឈើ ជ្រុះចុះពីលើ ទើរជិតគល់វា" ។

* * * *

## មេរៀនទី៨ អំពីមាតាបិតានឹងបុត្រធីតា

## Les devoirs des parents



ក្នុងសកលលោកនេះ មានចំនួនមនុស្សច្រើនអនេក មិនមែនក្រឡើយ ហើយសុទ្ធតែជាមាតាបិតា នឹងបុត្រធីតា នៃគ្នានឹងគ្នា ព្រោះថាមនុស្សយើងតែងកើតឡើងជាតំណគវង្ស ជាបច្ចាជនគា កើតចំនួនច្រើនឡើងៗ ជានិច្ចរាប់ទាំងរយលាន,

ប៉ុន្តែអ្នកប្រាជ្ញពោលថាកម្រមានទៅវិញ ។ ដែលថាកម្រមាននោះ គឺមិនសូវមានមាតាបិតានឹងបុត្រធីតា ដែលចេះទំនុកបំរុងសង្គ្រោះគ្នា ឲ្យបានត្រឹមត្រូវតាមបែបបទ ច្រើនតែត្រូវត្រង់ណោះខុសត្រង់ណោះ, បានបទនេះខ្វះបទនោះ, មិនងាយនឹងបានសព្វគ្រប់, ព្រោះហេតុនោះបានជាលោកថាកម្រមានក្នុងលោក ។ ឯបែបបទដែលមាតាបិតាទំនុកបំរុងបុត្រធីតាមានស្ថាន ៥ យ៉ាងគឺ :

១ - ចិញ្ចឹមបីបាច់រក្សាកូនឲ្យបានល្អប្រពៃ មិនថ្នាក់ថ្នមទម្រើសកូនឲ្យហួសហេតុ ឲ្យទាល់តែកូនធំចិត្តឡើងតាំងមិនកោតក្រែងត្រកូលរៀមច្បង. ប៉ុន្តែមិនត្រូវធ្វើបាបកូនដោយឥតមេត្តា, ក្នុងពេលដែលឃើញកូនធ្វើអំពើអាក្រក់ ប្រញាប់ប្រញាល់ឃាត់ហាមយ៉ាងម៉ឺងម៉ាត់ កុំបណ្តែតបណ្តោយឲ្យធ្វើតាមអំពើចិត្តពាល, ខំស្វា-ហ៍ប្រាប់ប្រដៅឲ្យស្គាល់ឲ្យជឿផលនៃទោសទុច្ចរិតក្នុងលោកនេះនឹងបរលោកដោយជាក់ស្តែង, ឲ្យកូនខ្លាចរអារញ្ញចិត្តគំនិតពាលបាលលែងហ៊ានប្រព្រឹត្តធ្វើនូវអំពើអាក្រក់ មានសម្លាប់សត្វលួចទ្រព្យគេជាដើមតទៅទៀត ។

២ – ប្រដៅឲ្យកូនរៀនកាន់សុចរិត ប្រព្រឹត្តល្អតាមគន្លងធម៌ច្បាប់, ឲ្យជឿស្តាប់ស៊ប់គំនិតពេញចិត្តស្រឡាញ់ផ្លូវត្រូវផ្លូវល្អ, បង្វឹកបង្វឺនកូនឲ្យស៊ប់ស៊ាំជ្ជកជែកក្នុងផ្លូវសុចរិត, ឲ្យកូនស្ថិតនៅក្នុងកុសល-ធម៌មានទានសីលជាដើម តាំងពីកាលនៅជាទារកតូច ៗ នៅឡើយ។

៣ – ប្រដៅហាមឃាត់ពត់ចិត្តគំនិតកូនឲ្យបង់បេះបង់ដង គឺមុនដំបូងបង្វឹកបង្វឺនកូនឲ្យរៀននិយាយ រៀនថាសំដីពោរី ដែលជាសំដីត្រឹមត្រូវច្បាស់លាស់ (វៀរបាកពាក្យដេរប្រទេច, ពាក្យអាក្រក់ និងពាក្យទំយើសំដីមាយាមិនច្បាស់លាស់ ដែលជាហេតុនាំឲ្យទារកធ្លាប់ ពិបាកនឹងកែទៅថ្ងៃមុខ) បង្ហាត់ឲ្យរៀនរាប់, រៀនថ្លឹង, រៀនស្ទង់, រៀនគ្នូរ, រៀនគិត, រៀនកាញ់, រៀនបូកសង គុណ ចែក, រៀនវាល់, រៀនវាស់, រៀនស្មានជាដើម ឲ្យថ្លឹកស្ទាត់ជំនាញតាំងពីនៅតូច ៗ មក, មិនបណ្តែតបណ្តោយឲ្យកូនជក់ចិត្តតែនឹងល្បែងផ្តេសផ្តាស នៅឆ្ងាស់តាំងគំនិតឬកអាប់ឥតប្រាជ្ញាក្នុងការបេះដង ៗ លុះដល់កូនមានអាយុចំរើនធំល្មមឲ្យរៀនចំណេះវិជ្ជាហើយ បានដាក់ទុកទំនុកបំរុងកូនឲ្យរៀនអក្សរសាស្ត្រ

នឹងវិជ្ជាផ្សេងៗតាមសមគួរដល់កាលៈ ទេសៈ នឹងសម័យលោកនិយម មិនបណ្ដោយឲ្យកូនទៅល្ងង់ខ្លៅទាំងប្រុសទាំងស្រី ៗ

៤– លុះដល់កូនស្ថិតនៅក្នុងវ័យផុតការសិក្សាហើយ គួររៀបចំឲ្យមានផ្ទះសម្បែងស្វាមីភរិយា តាមសេចក្ដីស្ម័គ្រស្មោះនៃសាមីរូបផង មិនបង់លើកកំពស់យកមុខយកមាត់ឲ្យគេអួតសរសើរ រៀបចំបុត្រធីតាឲ្យជាប់បង់ហួសហេតុហួសទំនងពេកផង, ខ្លួនក្រមិនឲ្យយកតម្រាប់អ្នកមានទ្រព្យ, មិនឲ្យដល់ថ្នាក់លក់ដីបញ្ចាំគេក្ដី ឬទុកបំណុលឲ្យកូនកើតទោមនស្សទៅថ្ងៃមុខ, បេះលៃឲ្យសមល្មមតាមកម្លាំងនឹងការគួរ មិនឲ្យខាសទំនង ៗ

៥ – ត្រូវលៃលកបំណាយប្រាក់កាសឲ្យកូនរៀនចំណេះវិជ្ជា, ឲ្យប្រាក់កាសកូនចាយវាយខ្ជះ, ទិញគ្រឿងប្រដាប់សម្លៀកបំពាក់ឲ្យកូនបានប្រើប្រាស់តាក់តែងខ្លួនគ្រប់គ្រាន់ សមរម្យដល់វ័យនឹងវង្សត្រកូលនឹងកាលសម័យ មិនតាញ់គេវតត្បិតកំប៉ុតកំប៉ូញហួសប្រមាណ ; កាលបើពិនិត្យទៅឃើញថា បុត្រធីតាអាចប្រកបការចិញ្ចឹមជីវិតកើតហើយ ក៏ជួយបណ្ដុះបណ្ដាលឲ្យបានកើតកាលវាលគុម្ព

ត្រជាក់ត្រជុំកុំបើចិនរងរឿង គឺចែកចាយទ្រព្យសម្បត្តិជនជានឲ្យធ្វើជាដើមទុន, ត្រូវចែកចាយឲ្យបានហើយស្រេច ហើយឲ្យត្រឹមត្រូវតាមលក្ខណៈច្បាប់សម្រាប់ប្រទេស កុំបីទុកឱកាសឲ្យកូនមានរឿងឈ្លោះទាស់ទែងដណ្តើមគ្នាដល់ក្រសួងតុលាការ ជាខាងក្រោយឡើយ ។ (ព្រះគ្រូសំសត្ថា ប. សុក្ខាដ)

*បោទស្សរ*:- មាតាបិតាត្រូវបំពេញកិច្ចជាដំបូង ដូចម្តេចខ្លះចំពោះកូន? កិច្ចទីពីរត្រូវធ្វើដូចម្តេចទៀត? មាតាបិតាត្រូវធ្វើដូចម្តេចទៀត ដើម្បីបង្ហាត់បង្រៀនកូន? ត្រូវរើសគ្រូដូចម្តេច ដើម្បីបង្ហាត់បង្រៀនកូន? មាតាបិតាត្រូវប្រដៅកូនបែបណាខ្លះ? បើធ្វេសប្រហែសមិនប្រដៅ តើកូននោះនឹងទៅជាដូចម្តេច? បើមានទ្រព្យសម្បត្តិត្រូវចែកឲ្យកូនដែរឬ?

* * * *

## មេរៀនទី ៩ បុត្រធីតាត្រូវទំនុកបំរុងមាតាបិតាវិញ ដោយស្មាន ៥ យ៉ាងគឺ:

## Devoirs des enfants envers leurs parents amour respect obéissance

១- បុត្រធីតាគាំងចិត្តថា: “អញដែលបានរស់រានមានជីវិត មានវ័យបានសេចក្តីសុខ-ចំរើនមកប៉ុណ្ណេះនេះ គឺដោយសារតែមាតា

បិតាលោកមានមេត្តាធម៌ បានថ្នាក់ថ្នមបីបាច់ចិញ្ចឹមរក្សា មិនឲ្យមានរោគរង្គំ តាំងតែពីតូចដរាបមក, ក្នុងពេលនេះលោកដល់នូវជរាភាព មិនគួរឲ្យលោកទៀយទឹងការចិញ្ចឹមជីវិតតទៅទៀតឡើយ



ហើយគប្បីផ្គត់ផ្គង់ទំនុកបំរុងចិញ្ចឹមរក្សាមាតាបិតា ឲ្យពេញលេញឲ្យដូចកាលដែលមាតាបិតាចិញ្ចឹមខ្លួន ។ បើឲ្យសមនឹងឋានៈនៃបុត្រធីតាជាកតញ្ញូកតវេទី អ្នកកើតមកក្នុងកាលជាខាងក្រោយនោះ គួរ

ណាស់តែខំប្រឹងប្រតិបត្តិចំពោះមាតាបិតា ចិញ្ចឹមថែទាំលោកឲ្យវិសេសលើសលុបជាងនោះទៅទៀត ។

២ – បុត្រធីតាត្រូវតាំងចិត្តថា: "កាលបើមាតាបិតាមានកិច្ចការរវល់, អញត្រូវបញ្ឈប់ការងាររបស់ខ្លួនទុកសិន" ហើយត្រូវធ្វើកិច្ចការជំនួសមាតាបិតា, មិនតោះតើយសោះអង្គើយបណ្តែតបណ្តោយឲ្យមាតាបិតានឿយហត់, វៀរលែងតែខ្លួនមានជម្ងឺជម្កាត់ៗ ពោះបើខ្លួនមានស្វាមីភរិយាបែកផ្ទះសម្បែងមុខរបរផ្សេងពីមាតាបិតាហើយ ក៏ត្រូវតែឈឺឆ្អាលជួយទុកធុរៈ ធ្វើកិច្ចការជូនមាតាបិតាក្នុងសម័យដែលគួរជួយដែរ, វេលាដែលជួយធ្វើនោះសោត បុត្រធីតាគប្បីធ្វើដោយស្មោះអស់ពីដៃពីជើង ហាក់ដូចជាការងាររបស់ខ្លួន, ឬបើបានលើសជាងនោះទៅទៀតក៏រឹងរឹតតែប្រសើរណាស់ ។

៣ – បុត្រធីតាត្រូវតាំងចិត្តថា "អញត្រូវដំកល់វង្សត្រកូលមាតាបិតាទុកឲ្យល្អមិនឲ្យវិនាស" ហើយមិនគប្បីបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់មាតាបិតាឲ្យវិនាសដោយការឥតប្រយោជន៍, គប្បីសង្គ្រោះមាតាបិតាឲ្យផុតអំពីវង្សដែលមិនប្រកបដោយធម៌ ឲ្យតាំង

នៅក្នុងវង្សដែលប្រកបដោយធម៌, មិនគប្បីផ្តាច់បង់នូវការកុសល តាំងឡាយមានការឲ្យទានប្រគេនចង្ហាន់បិណ្ឌបាតជាដើម ដែលមាតាបិតាធ្លាប់បានប្រព្រឹត្តធ្វើតាមគន្លងត្រូវល្អមកហើយ គឺមិនបំបាត់សណ្ដាប់ធ្នាប់ល្អរបស់មាតាបិតាឲ្យវិនាស, មិនប្រព្រឹត្តល្មើសរំលងនូវច្បាប់ល្អរបស់មាតាបិតា មិនធ្វើឲ្យអ្នកមានគុណកើតទុក្ខព្រួយចិត្តដោយសារខ្លួន ។

៤– បុត្រធីតាត្រូវគោរពប្រតិបត្តិរក្សាគំនិតមារយាទឲ្យល្អឲ្យជាទីស្រឡាញ់នៃមាតាបិតា ល្មមមាតាបិតាឲ្យទ្រព្យសម្បត្តិកេរ្តិ៍សម្បាច់, កាលបើមាតាបិតាបានប្រគល់ឲ្យហើយ, ត្រូវប្រុងប្រយ័ត្នរក្សាទ្រព្យសម្បត្តិកេរ្តិ៍អាករទាំងនោះឲ្យបានគង់នៅល្អ ឬឲ្យរឹងរិតតែចំរើនកើនល្អឡើង មិនបំផ្លិចបំផ្លាញឲ្យវិនាសខូចអស្សារឥតការ ។

៥– កាលបើមាតាបិតាធ្វើកាលកិរិយាហើយ, បុត្រធីតាត្រូវលើកសពសំស្ការដោយគោរព ត្រូវធ្វើទក្ខិណានុប្បទានឧទ្ទិសចំណែកផលបុណ្យ ជូនចំពោះមាតាបិតាឲ្យបានរឿយ ៗ ចាប់ដើមតាំងអំពីថ្ងៃដែលធ្វើមរណកាលទៅ ។

បើមាតាបិតានឹងបុត្រធីតាបានប្រព្រឹត្តត្រឹមត្រូវតាមស្ថានដែលត្រូវអនុគ្រោះត្រូវប្រតិបត្តិទៅវិញទៅមកយ៉ាងនេះហើយ, មាតាបិតានឹងបុត្រធីតានោះ ឈ្មោះថាបិទបាំងភ័យន្តរាយមិនឲ្យកើតឡើងបាន ឈ្មោះថាញុំាងសេចក្ដីសុខសម្រាន្តឲ្យកើតឡើងដល់ខ្លួន ពេញជាបុត្តការី ជាកតញ្ញូ កតវេទី ដោយត្រឹមត្រូវតាមលក្ខណៈច្បាប់ព្រះពុទ្ធសាសនា ។ (ប. សុម្ភាជ)

## ភាសិត-បិណ្ឌា

ឈាមល្អ មិនបេះកូតករ :

"ជនអ្នកមានពូជ មិនសូវខិលខូច ខាងផ្លូវមុសា ពោលតែពាក្យពិត
តាមវង្សកុលា អំបូរថ្លៃថ្លា ការកេរ្តិ៍អ្នកជា" ។

តេទស្សរ-- កិច្ចរបស់កូនត្រូវធ្វើដូចម្ដេចខ្លះចំពោះមាតាបិតាខ្លួន? ហេតុដូចម្ដេចបានជាត្រូវស្រឡាញ់មាតាបិតា នឹងត្រូវដឹងគុណតបគុណលោកវិញ? ត្រូវគោរពមាតាបិតាដូចម្ដេចខ្លះ? បុត្រធីតាត្រូវរក្សាវង្សត្រកូលដូចម្ដេចខ្លះ? កាលបើមាតាបិតាធ្វើកាលកិរិយាទៅ បុត្រធីតាត្រូវធ្វើអ្វីខ្លះចំពោះសពនោះ? បុត្រធីតាដែលបានប្រតិបត្តិមាតាបិតាយ៉ាងនេះហើយ ហៅកូនអ្វី?

* * * *

## មេរៀនទី ១០ ប្រព្រឹត្តល្អនឹងឪពុកធំ ម្ដាយធំ មា មីង

ឪពុកធំនឹងម្ដាយធំ គឺបងប្រុសបងស្រីខាងម្ដាយឪពុកយើង ៗ មាមីង គឺប្អូនប្រុសប្អូនស្រីម្ដាយឪពុកយើង ៗ ឲ្យកុមារស្រឡាញ់ ប្រណិប័តន៍គោរពខ្លាចអ្នកដែលត្រូវជាឪពុកធំម្ដាយធំមាមីង, ជួយទំនុកបំរុងក្នុងការធុរៈនឹងការពារក្នុងវេលាមានអន្តរាយ ៗ បើឥតពីមាតាបិតាយើង, ត្រូវឪពុកធំនឹងមានោះគ្រប់គ្រងបីបាច់រក្សាជាអាណាព្យាបាលជួសមាតាបិតាយើង ៗ ឯជាបងប្អូនជីដូនមួយនោះគឺជីដូនជីតាជាមួយគ្នា, ត្រូវឲ្យរាប់អានស្រឡាញ់គ្នា ជួយកិច្ចធុរៈគ្នាទៅវិញទៅមក បើនឹងធ្វើការអ្វីជាមួយគ្នាឲ្យតាំងចិត្តស្មោះត្រង់នឹងគ្នា ៗ

### ភាសិត

ត្រូវយើងទទួលនូវផល ដែលជីដូនជីតាយើងព្រោះសាបពីអតីតកាល ៗ

“គោរពចាស់ក្ដីចាំងបែងស្ពាងសែងអន្ត
ក្បួនសៀវភៅច្បាប់ឧភាសនិពសល្ងង់
សុភាសិតខន្ទេញសាកប្រាសចាកល្ងង់

កេរ្តិ៍ពូជពង្សប្រូលពឹងពាក់ក្តីជាក់ពិត ។

លោកជម្ទាទុកមាំមួនរៀនផ្ទួនតាំ

ដូចដំណាំលោកណែនាំថែទាំគិត

ឲ្យកូនចៅរៀនចាត់ចែងស្រោចទឹកនិត

រក្សាវឌ្ឍិះរកប្រូលចែងម្ហូប” ។

* * * *

## មេរៀនទី ១១ ការប្រព្រឹត្តិចំពោះជីដូនជីតា និងចាស់ទុំញាតិជិតខាង

### Devoirs envers les grands parents

ជីដូនជីតា គឺមាតាបិតានៃឪពុកម្ដាយយើង មានគុណលើឪពុកម្ដាយយើង ដូចឪពុកម្ដាយយើងមានគុណលើយើង ព្រោះបង្កើតឪពុកម្ដាយយើងមក ហើយព្រួយលំបាកនឹងបីបាច់ចិញ្ចឹមរក្សា ។ ឯយើងជាចៅត្រូវស្រឡាញ់ប្រណិប័តន៍គោរពខ្លាចជីដូនជីតា ហើយជួយទំនុកបំរុងកិច្ចការទាំងពួងឲ្យជាងញាតិទាំងពួង ព្រមទាំងគោរពចាស់ទុំនឹងញាតិជិតខាង ព្រោះជាកិច្ចទាក់ទងក្នុងគ្រួសារ ។

**ការអាន** មានកុមារម្នាក់អាយុ ១២ ឆ្នាំ ៗ ជីតានៃវាចាស់ជរាណាស់ អាយុ ៧៥ ឆ្នាំ ធ្មេញបាក់ សក់ស្កូវ ភ្នែកងងឹត មិនធ្វើការបរិភោគអាហារស៊ីពុំសូវបាន, មិនដើរចេញពីទីលំនៅទៅឯណា បើឥតឈើច្រត់ទៅពុំរួច, ដើរបានតែក្នុងរបងក្នុងភូមិ ៗ កុមារនោះមានចិត្តកតញ្ញូស្រឡាញ់ជីតា មកពីរៀនឯវត្តវេលាណា ខំបំរើជីតា លើកអាហារឲ្យជីតាបរិភោគ ដងទឹកឲ្យផឹកឲ្យងូតសព្វថ្ងៃជាប្រក្រតី ៗ ឯជីតានោះក៏មានចិត្តស្រឡាញ់ចៅដែលប្រព្រឹត្តប្រណិប័តន៍ល្អ ៗ ឯតាចាស់នោះចាំរឿងទំនៀមទំលាប់ជាច្រើន ៗ រាល់យប់ វេលាមុនចូលដេក គាត់និយាយរឿងពង្សាវតារព្រេង ឬទំនៀមទំលាប់ឲ្យចៅស្តាប់ ៗ ចៅនោះស្តាប់រួចហើយ ក៏យកសាស្ត្រាមកមើលមកទេសមកសូត្រឲ្យជីតាស្តាប់ទំរាំដល់ងងុយដេក ៗ ដល់ព្រឹកឡើង កុមារនោះបំរើជីតាដងទឹកឲ្យលុបមុខ ថែទាំបោសច្រាសដំណេកជីតារួចស្រេច ទើបកណ្តៀតសៀវភៅទៅវត្ត ៗ ថ្ងៃសីល កុមារនោះខានទៅវត្ត មិនហ៊ានដើរទៅលេងឯណាឆ្ងាយពីជីតាដល់រកហៅពុំឮ

នោះឡើយ ។

បើកុមារនោះឃើញជីតាមុខស្លូត ពុំសូវរីករាយដូចសព្វដង យល់ថាជីតាអផ្សុក, ក៏បបួលជីតាដើរចេញទៅលេងក្រៅរបងលំហែចិត្តឲ្យបាត់អផ្សុក ។ ជីតាក៏ចូលចិត្តតាមចៅដែលឲ្យគាត់ស្មាជួយអង់គាំពារឲ្យដើរបានដោយស្រួល ។

កុមារទាំងឡាយគប្បីយកគម្រាប់តាមកុមារដែលសំដែងមកនេះ ។

ម្យ៉ាងទៀត ត្រូវគោរពចាស់ព្រឹទ្ធាចារ្យ ញាតិជិតខាងខ្លួន ឲ្យដូចជាគោរពស្រឡាញ់ឪពុកធំ មា មីង យើងដែរ, គោរពជួយធុរៈការងារគ្នាទៅវិញទៅមក, ជួយថែទាំជម្ងឺ ជួយដោះទុក្ខធុរៈគ្នា បើមានអាសន្នកើតឡើង ។

ដូចមានភាសិតបុរាណថា "អ្នកដែលមានញាតិជិតខាងល្អ ដេកលក់ទាល់តែព្រឹក ។

"នៅជិតសប្បុរស សុខស្រួលទាំងអស់ ឥតទុក្ខឥតភ័យ នៅជិតជនពាល មានតែចង្រៃ ព្រួយចិត្តរាល់ថ្ងៃ មិនបានក្តីសុខ" ។

ចោទសួរ.- កូនចៅត្រូវតាំងចិត្តដូចម្តេចខ្លះចំពោះជីដូនជីតានិងឪពុកធំម្តាយធំ

មាមីងញាតិសាលោហិតជិតខាង? ហេតុដូចម្ដេចបានជាត្រូវស្រឡាញ់ជីដូនជីតាមាមីងឪពុកធំម្ដាយធំ? កិច្ចអ្វីខ្លះដែលយើងត្រូវធ្វើចំពោះចាស់ព្រឹទ្ធាចារ្យ? តើស្គាល់បានថាជាក្មេងល្អដោយគុណធម៌ ដូចម្ដេច? ចូរលើកភាសិតខ្លះមកអាងពីមនុស្សដែលមានញាតិជិតខាងល្អ!

ឲ្យសិស្ស ២-៣ នាក់និយាយរៀងពីដើមមកវិញ ។

*   *   *   *

## *មេរៀនទី ១២* សេចក្ដីប្រព្រឹត្តិចំពោះបងប្អូនប្រុស-ស្រី

**Devoirs réceproques des frères et des sœurs**

*បងប្អូនបង្កើតនឹងគ្នា ទោះប្រុសក្ដីស្រីក្ដី ត្រូវឲ្យស្រឡាញ់គ្នាទៅវិញទៅមក ហេតុនេះបងត្រូវថ្នមប្អូនៗត្រូវប្រណិប័តន៍គោរពខ្លាចបង បើនិយាយទៅមកកាន់គ្នា ឲ្យមានពាក្យគួរសម នោះទើបនឹងរក្សាសេចក្ដីស្នេហាគ្នាបាន ។ បងត្រូវថែទាំទំនុកបំរុងប្អូន ទូន្មានប្រដៅឲ្យដឹងកិច្ចការរាក់ជ្រៅខ្ពស់ទាបល្អអាក្រក់គុណទោសគួរសម, កាន់ឥរិយាបថឲ្យល្អឲ្យគាប់ជាដរាបឲ្យប្អូនប្រព្រឹត្តតាម ។ ឯប្អូនមិនត្រូវប្រមាថបង ត្រូវគោរពទុកដាក់ខ្លួនជាតូចជាង, បើបងមានពាក្យធំតូចត្រេតោះលើសលស់ដោយហេតុឯណានីមួយ, ត្រូវប្អូនអត់សង្កត់ចិត្ត កុំខឹងឆ្លើយតបប្រកួតប្រកាន់នឹងបងវិញ ត្រូវបៀសវាងដើរ*

ឆ្ងាយ ៗ ឯបង បើប្អូនមានពាក្យគ្រោតគ្រោះលើសលស់បន្តិចបន្តួច, កុំឲ្យប្រកាន់ ត្រូវតែរំពឹកគ្នាទៅវិញទៅមក ទើបហៅថាប្រព្រឹត្តល្អនឹងបងប្អូន ៗ ឯបងប្អូនស្រី ខ្លួនយើងជាប្រុស បើនឹងមានដំណើរទៅណាមកណា គោងមើលថែទាំជួយការពារ កុំឲ្យមនុស្សដទៃមើលងាយ, ត្រូវជួយធុរៈគាត់ក្នុងកិច្ចការធ្ងន់ៗជាដើម ៗ បំណែកបងប្អូនស្រី ៗ ត្រូវមើលផ្គត់ផ្គង់ម្ហូបអាហារ ដេរសម្លៀកបំពាក់ ។ល។ ជារបស់បងប្អូនប្រុសរបស់ខ្លួន ដំនួសមាតា ៗ ត្រូវស្រឡាញ់រាប់រកគ្នាឲ្យណាស់ ត្រូវជួយការពារវង្សត្រកូលឲ្យបានរុងរឿងល្អតទៅថ្ងៃទៅ, ឲ្យសមនឹងពាក្យបុរាណថា "កូនមានពូជល្អ" ។

*សោទស្សរ..* ចូរទាញហេតុ ដែលនាំឲ្យបងប្អូនប្រុសស្រីបង្កើតស្រឡាញ់រាប់រកគ្នា! បងប្អូនដែលធ្វើខុសឆ្គងដោយហេតុឯណានីមួយ តើត្រូវធ្វើដូចម្ដេចរវាងគ្នានឹងគ្នា? កិច្ចធុរៈរបស់បងស្រីដូចម្ដេចខ្លះ? យើងត្រូវបំពេញទឹកចិត្តដូចម្ដេចខ្លះ ឲ្យឃើញថាយើងជាបងប្អូនស្រឡាញ់គ្នាពិតប្រាកដ?

* * * *

## មេរៀនទី ១៣ ការប្រព្រឹត្តនឹងមិត្តសំឡាញ់

**Devoirs envers les amis**

ដែលហៅថាមិត្តសំឡាញ់នឹងគ្នានោះគឺ មនុស្សអ្នកដទៃ មិន

មែនជាញាតិសាលោហិត, តែបានស្គាល់ឬកកិរិយានឹងសំដីគាប់ចិត្តគ្នាទៅវិញទៅមក ក៏ចងមេត្រីរាប់អានគ្នា ៗ បើបានជាមិត្រសំឡាញ់នឹងគ្នាដូច្នេះហើយ, ត្រូវគិតរក្សាសេចក្ដីមេត្រីនឹងគ្នានោះឲ្យបានអង្វែងតទៅ ៗ ហេតុដូច្នេះគួរប្រព្រឹត្តតាមដម្បូន្មានក្នុងបរិសាស្ត្រយ៉ាងនេះ:

១ កុំឲ្យរិះគន់ហើយនិយាយដើមពីគ្នា ឲ្យមានការរាប់អានគ្នាតាមធំតាមតូច

២–ឲ្យជួយធុរៈគ្នាទៅវិញទៅមក, បើនឹងធ្វើការរកប្រយោជន៍នីមួយ ៗ របស់ខ្លួន ឲ្យគិតដល់ប្រយោជន៍មិត្រនោះផង, បើឃើញថាធ្វើការនោះទៅត្រូវខូចប្រយោជន៍មិត្រ នោះកុំឲ្យធ្វើត្រូវតែឈប់

៣ – នៅក្នុងវេលាប្រឹក្សាការនឹងគ្នា ឬបរបានិយាយគ្នាក្នុងទីប្រជុំជនជែកគ្នាពីរឿងអ្វី ៗ នោះ កុំប្រើសំឡេងគ្រគោះ កុំប្រើកិរិយាសង្កត់មិត្រ ៗ

## ភាសិត_បិត្តា

ស៊ូដើរទៅម្នាក់ឯង បើរកមិត្រល្អពុំបាន ៗ

បើមិត្រទ័លក្រលំបាក ត្រូវទៅរក ។

បើមិត្រមានភោគ ឬមានសក្តិ ត្រូវធំចាំ ។

ចោទសួរ.. ដូចម្តេចដែលហៅថាមិត្រសំឡាញ់? ត្រូវធ្វើកិច្ចអ្វីខ្លះរវាងគ្នានឹងគ្នា? ត្រូវរក្សាចិត្តដូចម្តេច ដើម្បីឲ្យបានចំណងមេត្រីនេះឋិតថេរវែងទៅ? ធុរៈអ្វីខ្លះដែលត្រូវជួយគ្នាទៅវិញទៅមក? ចូរទាញភាសិត_បិត្តាខ្លះក្នុងរឿងមិត្រភក្តិ? ឲ្យសិស្ស ២-៣នាក់និយាយរៀងពីដើមឡើងវិញ ។

* * * *

## មេរៀនទី ១៨ ការប្រព្រឹត្តទៅវិញទៅមករវាង ចៅហ្វាយនាយនឹងខ្ញុំកំដរ

## Devoirs réciproques des maîtres et des serviteurs

១ - ចៅហ្វាយនាយត្រូវទុកប្រហែលគ្នានឹងកូនចៅក្នុងគ្រួសារ ជាមួយគ្នា អស់ទាំងបាវព្រាវកូនឈ្នួល, មិនត្រូវទុកមនុស្សទាំងនេះ ដូចជាមនុស្សអ្នកដំណើរក្រៅផ្ទះ ឬទុកមនុស្សទាំងនេះដូចជាខ្ញុំកញ្ជះ ក្រោមបាតជើង ដូចមនុស្សជាន់ដើមបានប្រព្រឹត្តមកនោះឡើយ ។

អធិប្បាយថា : ចៅហ្វាយនាយត្រូវចេញឈ្នួលឲ្យខ្ញុំកំដរ កូនគូលីតាមថ្ងៃឈ្នួល, មិនត្រូវបំភិតបំភ័យប្រើប្រាស់ឲ្យធ្វើការងារហួស

កម្លាំង, ត្រូវបើកឲ្យមានពេលឈប់សម្រាក, ត្រូវថែទាំជម្ងឺក្នុងការឈឺថ្កាត់, ធ្វើចិត្តល្អមានមេត្តាករុណា ដើម្បីឲ្យមនុស្សនៅផងទុកចិត្តស្រឡាញ់ដូចជាឪពុកនឹងកូន, ត្រូវខ្លួនប្រដៅឲ្យបានល្អ, ត្រូវទទួលបន្ទុកការខុសត្រូវលើខ្លួនផងក្នុងកាលដែលមានហេតុ ។

២– **ចំណែកខាងខ្ញុំកំដរបាវព្រាវត្រូវបំពេញករណីយកិច្ចជូនចៅហ្វាយនាយក្នុងការនោះៗវិញ ។**

អធិប្បាយថា : ពុ.វព្រាវកូនឈ្នួលត្រូវធ្វើការងារឲ្យចៅហ្វាយនាយឲ្យហ្មត់ចត់ ឲ្យដូចជាការងាររបស់ខ្លួនដែរ, មិនត្រូវខ្ជះខ្ជាយ, ត្រូវជួយធ្វើការណាដែលជាការប្លែកលើសពីការធម្មតា ដែលជាការប្រញាប់ៗ; រួបរួមទៅគឺត្រូវខំស្វាហាប់ធ្វើកិច្ចការឲ្យចៅហ្វាយនាយដោយយកចិត្តទុកដាក់ស្មោះត្រង់ ។

៣ – **ដោយសេចក្តីទុកចិត្តរាប់អានរបស់ចៅហ្វាយនាយ ខ្ញុំកំដរត្រូវស្រឡាញ់ចៅហ្វាយនាយដោយស្មោះត្រង់ ។**

អធិប្បាយថា : ការណាស្ទាត់កំប៉ាំង ឬការណាធំៗ ដែលយើងជាបាវព្រាវតែងដឹងដោយធ្លាប់នៅជាមួយគ្នា ដូចជាគ្រួសារ

តែមួយនោះមិនត្រូវនិយាយនាំអុបអាលឲ្យអ្នកដទៃដឹងឮទេ មិនត្រូវនិយាយដើមពីម្ចាស់ឡើយ ត្រូវជួយថែទាំជម្ងឺម្ចាស់ ។

៤- កុមារទាំងឡាយត្រូវប្រព្រឹត្តឲ្យល្អនឹងបាវព្រាវខ្ញុំកំដររបស់ខ្លួនដែលមាន, ត្រូវរាប់រកស្រឡាញ់ដោយស្មោះស្ម័គ្រដូចជាបងប្អូនបង្កើត, មិនត្រូវពោលត្រគោះបោះបោកទៅរក ដោយអាងថាខ្លួនជាចៅហ្វាយនាយនោះទេ, មិនត្រូវធ្វើឲ្យអាក់អន់ស្រពន់ចិត្ត ដើម្បីធ្វើឲ្យបាវព្រាវខ្ញុំកំដរមិនទុកចិត្តស្រឡាញ់ឡើយ ។

## ភាសិត_បិត្តា

ចៅហ្វាយនាយយ៉ាងណា បាវព្រាវក៏យ៉ាងនោះ ។

ចៅហ្វាយនាយល្អ បាវព្រាវក៏ល្អ ។

ការងារឯណាល្អ, ការងារទាំងនោះគឺជាការងារសុចរិត ។

បើអ្នកចង់រកបាវព្រាវឲ្យបានសុចរិតពិតត្រង់ហើយឲ្យត្រូវចិត្តខ្លួនផង តោងតាំងខ្លួនឯងជាអ្នកធ្វើខ្លួនឯង ។

ត្រូវកាត់ភោមបៀមញី កុំពន្លះស្បែករាចេញ ។

"ប្រើបាវមើលចិត្តវា កុំពុះពារផុតប្រណី សត្វបម្រើសោតខ្ញុំ ត្រូវមេត្រីឲ្យស្មោះទឹក" ។

កិច្ចលំបាកដែលធ្វើ ត្រូវតែមានថ្ងៃឈ្នួល ។

"ប្រើគោឲ្យធីស្មៅ ប្រើដនទៅឲ្យបាយហូប ប្រើសេះឲ្យទឹកស្រួប បើធ្លាញ់ម្ហូបទឹកបាវព្រាវ" ។

ត្រូវដាក់គណ្ដឹងកណ្ដាលព្រះវិហារ ។

"មនុស្សឃ្លានត្រូវឲ្យបាយ កើតរោគកាយឲ្យឱសថ ឲ្យម្ជុលបន្ទាមុត ចង់ត្រូវបចឲ្យគាន់ច្បាប់" ។

អ្នកណាចង់ធ្វើដំណើរឆ្ងាយ, ត្រូវសន្ដោសដល់យានជំនិះ ។

"ធ្វើការស្គាល់កាល ស្គាល់កិច្ចធ្ងន់ស្រាល ប្រើមនុស្សពាសា ឲ្យរង្វាន់ប្រាក់ ប្រើគោមហិង្សា ឲ្យស្មោះពោលថា មេត្តាច្បាប់លោក" ។

ចៅហ្វាយនាយល្អ បេនាពាសាឲ្យបានល្អ ។

"ចៅហ្វាយនាយសោភ័ណ ពាសាវណ្ណវេញសោភា បាន ឆ្គង់គាពសិលា ម្ចាស់គ្រឹះហាមិនប្រដៅ" ។

ចោទសួរ.- ត្រូវទុកខ្ញុំកំដរដូចជាមនុស្សអ្នកដំណើរក្រៅផ្ទះឬដូចម្ដេច? ត្រូវធ្វើដូចម្ដេចចំពោះខ្ញុំកំដរ? កិច្ចអ្វីខ្លះដែលខ្ញុំកំដរត្រូវបំពេញមកម្ចាស់ជាចៅហ្វាយនាយវិញ? ត្រូវធ្វើដូចម្ដេចឲ្យឃើញថា ខ្ញុំកំដរមានចិត្តស្មោះត្រង់ស្រឡាញ់រាប់រកចំពោះម្ចាស់មែន? កូនចៅត្រូវគិតធ្វើដូចម្ដេចចំពោះបាវព្រាវដែលនៅក្នុងផ្ទះជាមួយ? ក្នុងខណៈដែលម្ចាស់ក្ដីបាវព្រាវក្ដីមានជម្ងឺ តើអ្នកទាំងពីរនេះត្រូវប្រព្រឹត្តរវាងគ្នានឹងគ្នាដូចម្ដេចខ្លះ? ចូរទាញភាសិត-បិដ្ឋាខ្លះក្នុងរឿងនេះ ។

## ការអាន

## ការនៅជាសុខឥតក្ដីភិតភ័យ បាត់ជាការប្រសើរ

មានសត្វកណ្ដុរ ២ តួជាសម្លាញ់នឹងគ្នា ៗ កណ្ដុរ ១ នៅក្នុងផ្ទះ, កណ្ដុរ ១ នៅក្នុងព្រៃ ។ ថ្ងៃមួយកណ្ដុរផ្ទះបបួលកណ្ដុរព្រៃទៅស៊ីលៀងជាការសប្បាយតាមគាសាជាមិត្រនឹងគ្នា ។ ឯកណ្ដុរទាំងពីរកាលកំពុងបរិភោគចំណី បានឮសូរមនុស្សគោះទ្វារគោះបង្អួចលាន់ម៉ឺងម៉ាំងក៏កើតក្ដីតក់ស្លុតភិតភ័យមើលឆ្វេងមើលស្ដាំ ហើយសំងំស៊ីទៅទៀត; លុះស៊ីទៅក៏ឮសូរសន្ធឹកជើងមនុស្សដើរចូលមក ៗ កណ្ដុរទាំងពីរក៏រឹងរិតតែភិតភ័យឡើងទៀតរកតែផ្លូវនឹងរត់គេច ។ ការអាស្រ័យលៀងនោះ ក៏ពុំមានផលជាសេពសាឡើយ ព្រោះក្ដីភ័យខ្លាច

ក្រែងមនុស្សប្រុសត្នាវាយាយី, ម្ល៉ោះហើយក៏ស៊ីបន្តិចបន្តួចបន្ទាន់ពេលហើយរត់ទៅកាន់លំនៅនៃអាត្មាទៃ ៗ ថ្ងៃក្រោយ កណ្ដុរព្រៃបបួលកណ្ដុរផ្ទះទៅស៊ីលៀងឯទីវាលស្រែព្រៃវិញ ៗ ឯគ្រឿងម្ហូបចំណីរបស់កណ្ដុរព្រៃនោះ ពុំសូវល្អ ព្រោះជាជាតិអ្នកថោកទាប; ប៉ុន្តែកាលដែលបរិភោគនោះ ពុំមានមនុស្ស ប្រុសត្រូណាដើរដិតខាងនាំឲ្យភ្ញាក់ផ្អើលឡើយ ៗ កណ្ដុរទាំងពីរស៊ីលៀងដោយសប្បាយដរាបដល់ឆ្អែតស្កប់ស្កល់រៀងខ្លួន ៗ លុះស៊ីលៀងហើយកណ្ដុរផ្ទះនិយាយបំអួតត្នះតិះដៀលថា ម្ហូបចំណីរបស់មិត្តឯងនេះ អន់ទន់ទាបភាពអ្នកព្រៃ ដោយពុំចេះបាត់បែងឲ្យល្អដូចគេអ្នកស្រុកឡើយ ស៊ូទីងម្ហូបចំណីខ្ញុំឯងនេះមិនបានទេ ៗ ឯកណ្ដុរព្រៃក៏តបថា មែនហើយមិត្តឯងថានោះ! ក្នុងថ្ងៃមុនខ្ញុំបានទៅទទួលទានភោជនាហាររបស់មិត្តឯង; ឯម្ហូបចំណីមិត្ត ក៏សុទ្ធសឹងតែល្អ ៗ, ប៉ុន្តែលេមទៅស្ទើរតែស្ទះបំពង់កស្លាប់ជាម្ដង, ស៊ីទាំងភ័យទាំងភិតបាត់រស់ឆ្ងាញ់ពិសាក្នុងការលៀងនោះ; ឯម្ហូបចំណីរបស់ខ្ញុំអន់ទន់ទាបពិត, ប៉ុន្តែបរិភោគទៅឥតក្ដីតក់ស្លុតភិតភ័យ, គិតទៅយល់ថាវិសេសជាងចំណីល្អ ចំណីខ្ពស់ ព្រោះ

ឥតមានក្ដីតក់ស្លុតជាអារម្មណ៍ នាំឲ្យស៊ីបាយមិនបាននោះឯង, ប្អមិត្រឯងយល់ថាចំណីនណោវិសេសលើសចំណីនណោ? ឯកណ្ដុរផ្ទះឮដូច្នោះ ក៏ពុំអាចតបថាអ្វីទៅទៀតឡើយ ហើយក៏លាកណ្ដុរព្រៃវិលទៅកាន់លំនៅនៃអាត្មាវិញហោង ។

សួរ— រឿងនិទាននេះ បានគតិយ៉ាងណា ចូរឯងថាទៅមើល?

* * * *

## មេរៀនទី ១៥ សង្គហវត្ថុ

នឹងពោលអំពីសង្គហវត្ថុដែលជាហេតុឲ្យមនុស្សមានឈ្មោះថា បុព្វការី នឹងកតញ្ញូកតវេទី ។ បុត្រនឹងធីតាជាដើម ដែលបានប្រព្រឹត្តតាមបែបបទដូចពណ៌នាមកខាងលើនេះហើយ បើពុំចេះឧបាយសម្រាប់ស្រោចស្រង់សង្គ្រោះប្រតិបត្តិគ្នាទៅវិញទៅមកទេ, ក៏នឹងមិនបានជាទីគោរពបូជា ជាទីស្រឡាញ់រាប់អាននៃគ្នានឹងគ្នាឡើយ ។ ព្រោះហេតុនេះបានជាអ្នកប្រាជ្ញពុទ្ធសាសនាសំដែងសង្គហធម៌ដែលជាធម៌សម្រាប់ប្រមូលជនទាំងឡាយឲ្យមូលគ្នាក្នុងលោក ឲ្យជាទីពេញចិត្តស្និទ្ធស្នេហ៍ទៅវិញទៅមក ថាមាន ២[១] ប្រការគឺ:

(១) បើតាមផ្លូវធម៌សុទ្ធថាមាន ៤ យ៉ាង ។

១-ទាន: ការចែករំលែកឲ្យវត្ថុដោយសង្គហៈ ជាឧបាយយឹតយោងចិត្តរបស់អ្នកទទួលឲ្យចូលចិត្តស្និទ្ធស្នាលរាប់រក មានមាតាបិតានិងបុត្រធីតាជាដើម ដែលសង្គ្រោះគ្នាទៅវិញទៅមក ។ ប៉ុន្តែមិនត្រឹមតែឲ្យប៉ុណ្ណោះទេ បើមិននិយាយពាក្យពីរោះគួរជាប់ចិត្តផង ទោះបីឲ្យវត្ថុច្រើនក៏ប្រាកដហាក់ដូចជាតិច ។ បើចេះនិយាយពាក្យពីរោះពិសាគួរឲ្យស្រណោះជាប់ចិត្តថែមទៀតនោះ ក៏វត្ថុការដែលឲ្យសូម្បីតិចតួចក៏ប្រាកដហាក់បីដូចជាច្រើន ព្រោះធ្វើឲ្យកើតសេចក្តីស្រឡាញ់ស្មោះស្ម័គ្រ ។ ព្រោះហេតុនោះបានជាអ្នកប្រាជ្ញខាងពុទ្ធសាសនា សំដែងសង្គហវត្ថុ ទីពីរថា:

២- បិយវាចា ពាក្យពីរោះគួរជាប់ចិត្ត មានពីរប្រការគឺ:

ក) សំដីពីរោះទន់ផ្អែម ធ្វើអ្នកនិយាយឲ្យជាទីស្រឡាញ់របស់អ្នកស្តាប់ ។

ខ) សំដីប្រកបដោយប្រយោជន៍ ។

អ្នកដែលខំស្វាហាប់និយាយពាក្យពីរោះ ពាក្យនាំឲ្យកើតប្រយោជន៍ នោះអាចទន់ទាញកៀងចិត្តមនុស្សឲ្យទន់ទោរមកបាន ។

មាតាបិតានឹងបុត្រធីតាដែលចេះនិយាយស្តីពីរោះពិសាទៅវិញទៅមក រមែងជាទីស្រឡាញ់ស្និទ្ធស្នាលរាប់អានគ្នានឹងគ្នា ។

អ្នកដែលមិនប្រសប់វៃឈ្លាសក្នុងការធ្វើបដិសណ្ឋារៈពាក់ទាក់ស្រួលរាយចំពោះភ្ញៀវតទ្ទឹ រមែងជាទីស្រឡាញ់ចូលចិត្តរបស់មនុស្សទាំងឡាយ អាចញ៉ាំងអ្នកតូចឲ្យមានបំណង់ធ្វើកិច្ចការដោយសេចក្តីសុចរិតស្មោះត្រង់ប្រឹងប្រែង; សូម្បីតែសត្វតិរច្ឆានក៏ចូលចិត្តតែនឹងសំដីពីរោះដែរ ដូចគោនន្ទវិសាល ដែលមានដំណាលក្នុងគម្ពីរឯក-និបាតជាតកថា គោឈ្មោះនន្ទវិសាល បានស្តាប់សំដីល្អទំលោមជាទីគាប់ចិត្តអំពីសំណាក់នៃព្រាហ្មណ៍ជាម្ចាស់ហើយ ក៏ខំប្រឹងអូសរទេះផ្ទុករបស់ធ្ងន់ៗ ដែលចងសណ្តោងភ្ជាប់គ្នាជាច្រើនទៅរួច, អាចឲ្យព្រាហ្មណ៍ជាម្ចាស់ឈ្នះការភ្នាល់ បានប្រាក់ចំនួនមួយពាន់កហា-បណៈពីសេដ្ឋី ។

## ការបញ្ជាក់ឡើងវិញ – ការដាក់ឲ្យធ្វើ

១-គ្រួសារ: ការរួបរួមគ្រួសារ, មុខការរបស់សមាជិកនីមួយៗចំពោះគ្រួសារ, ចិត្តថ្មើមស្មោះត្រង់ ដើម្បីឲ្យបានមូលមិត្តគ្នាជា

អន្ទ្រងទៅ, សេចក្ដីថ្លៃថ្នូរក្នុងគ្រួសារ ។

២–ចូរអធិប្បាយចិន្ដាដូចតទៅនេះ “ការបូជានឹងការស៊ូប្ដូរជីវិតនេះឯង ជាជីវិតរបស់មាតាម្នាក់” ។

៣ – ដូចម្ដេចដែលថា ទុកៈទាសឲ្យកូន គឺធ្វើកូនឲ្យរងទុក្ខលំបាកទៅថ្ងៃក្រោយ ដោយបណ្ដែតបណ្ដោយថ្មក់ពីតូចឲ្យទាល់តែខូច ?

៤ – ចូរពន្យល់ពាក្យបិតាជាមេគ្រួសារម្នាក់ ដែលពោលថា : “ខ្ញុំបំណាយធនធានមួយចំណែកក្នុងការទំនុកបំរុងការសិក្សារបស់កូនខ្ញុំ; ធនធាននេះទុកជាប្រាក់សម្រាប់ចងការដែលមានកម្រៃយ៉ាងសម្បើម” ។

៥ – ចូរអធិប្បាយអំពីកូនមិនស្ដាប់ដំបូន្មានឪពុកម្ដាយ និងកូនមិនដឹងគុណទោស ។

៦–កូនបានជាធំលើសឪពុកម្ដាយ, តើកូនយ៉ាងនេះត្រូវធ្វើដូចម្ដេចចំពោះមាតាបិតាខ្លួន ?

៧–បងប្អូនជីដូនមួយរបស់អ្នក ឪពុកម្ដាយស្លាប់ចោល, ឪពុក

ម្ដាយអ្នកតាំងខ្លួនជាអ្នកចិញ្ចឹមវា, តើអ្នកត្រូវធ្វើដូចម្ដេចចំពោះវា?

៨ – មានគូកនម្នាក់មកបបួលអ្នកឲ្យទៅលេងជាមួយនៅវេលាដែលអ្នកកំពុងមើលសៀវភៅឲ្យជីដូនអ្នកស្ដាប់ អ្នកត្រូវធ្វើដូចម្ដេច ?

៩ – គោរពប្រតិបត្តិចាស់ដូចម្ដេច ?

១០ – សេចក្ដីសង្គ្រោះបងប្អូនដូចម្ដេចខ្លះ ?

១១ – ចូរអធិប្បាយពីការប្រព្រឹត្តិរបស់កូនជាបងៗ ត្រូវធ្វើដូចម្ដេចចំពោះប្អូនៗ ?

១២ – កុមារីជាមេផ្ទះអ្នកធ្វើបាយទឹកសម្រាប់គ្រួសារ តើត្រូវប្រើអាការកិរិយាបំរើបែបណាខ្លះ ចូរអធិប្បាយ ?

# ជំពូកទី ៣

# chapitre 3

# សាលារៀន

# L'école

## មេរៀនទី ១៦ គ្រូនឹងសិស្ស

## Les maitres et les éléves



សាលារៀនជាប្រភព (កន្លែង) នៃការសិក្សា របស់កុលបុត្រទាំងឡាយ, សាលារៀនទុកដូចជាប្រទីប ជាកូនសោរ ជាទ្រើង ឬទុកដូចជាអាវុធរបស់កុមារទាំងឡាយ ដែលមានគ្រូអាចារ្យជាអ្នក

បំភ្លឺផ្លូវ ៗ ប្រទេសណាដែលសម្បូណ៌សាលារៀន, ប្រទេសនោះ តែងចម្រើនរុងរឿងដោយពលរដ្ឋអ្នកចេះដឹងច្រើន អាចធ្វើប្រទេសជាតិ មាតុភូមិឲ្យសម្បូណ៌ដោយភោគទ្រព្យ ៗ

សាលារៀនមានច្រើនបែបច្រើនជាន់ច្រើនថ្នាក់ គឺ:

ប្រថមភូមិជាន់ដម្បូង=កុមារដ្ឋាន, បរិវុឌ្ឍដ្ឋាន, អាទិកដ្ឋាន ៗ

ប្រថមភូមិបំពេញវិជ្ជា=មធ្យមដ្ឋានឆ្នាំទី១, មធ្យមដ្ឋានឆ្នាំទី២, ឧត្តមដ្ឋាន ៗ

ប្រថមភូមិជាន់ខ្ពស់=ថ្នាក់ឆ្នាំទី១, ឆ្នាំទី២, ឆ្នាំទី៣, ឆ្នាំទី៤ ប្រឡងយកសញ្ញាប័ត្រ(ឌីប្លូម) ៗ

មធ្យមសិក្សាទំនើបសម្រាប់ជាតិ=ថ្នាក់ទី ៦,-ទី ៥,-ទី ៤, -ទី ៣,-ទី ២,-ទី ១, ប្រឡងយកមធ្យមសិក្សាប័ត្រ (ឬស្យូ)ៗ

សាលាគរុវិជ្ជាបរិវុឌ្ឍនដ្ឋានគរុកោសល្យ, សាលាវិជ្ជាជីវៈសិក្សា, មហាវិទ្យាល័យ ៗ

ចោទសួរ.. ដូចម្ដេចហៅថាសាលារៀន? អ្នករៀននៅសាលាណា? អ្នកស្គាល់សាលាណាខ្លះក្នុងខេត្តអ្នក? សាលាមានប៉ុន្មានបែប ហើយបែកចេញទៅជា

ថ្នាក់មានប៉ុន្មានក្នុងសាលានីមួយៗ? ដូចម្ដេចហៅថា មហាវិទ្យាល័យ? ឲ្យសិស្ស ២ ឬ ៣ នាក់ ឈរឡើងនិយាយរៀបរាប់ពីដើមមកវិញ ។

## សញ្ញាប័ត្រសិក្សា

វិញ្ញាបនប័ត្រ, ប្រកាសនីយប័ត្រ, សញ្ញាប័ត្រគរុកោសល្យសម្បទា, វិញ្ញាបនប័ត្របំពេញបឋមសិក្សា, វិញ្ញាបនប័ត្រគរុកោសល្យសម្បទាបារាំង-ខ្មែរ, សញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់, ប្រកាសនីយប័ត្រគរុកោសល្យសម្បទា, វិញ្ញាបនប័ត្រចប់ការរៀនគរុវិជ្ជាខ្មែរ, សញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់នៃគរុវិជ្ជាខ្មែរ, ប្រកាសនីយប័ត្រជាន់ដំបូង, ប្រកាសនីយប័ត្រមធ្យមសិក្សា, ប្រកាសនីយប័ត្រគរុវិជ្ជាឧត្ដមាគមន៍ ឬមហាបរិញ្ញាប័ត្រថ្នាក់បណ្ឌិត, សញ្ញាប័ត្រថ្នាក់បណ្ឌិត, បរិញ្ញាប័ត្រ ៗ

## បុគ្គលិកក្រសួងសិក្សាធិការ

គ្រូបង្ហាត់, គ្រូជំនួយ, គ្រូបង្រៀន, សាស្ត្រាចារ្យ, ចាងហ្វាងសាលា, អធិការ, អធិការនាយក, គ្រូបង្ហាត់សិក្សាតិកទិក, គ្រូបង្ហាត់កាយសិក្សា, គ្រូបង្ហាត់វិជ្ជាជីវៈ ៗ

សួរចោទ.. សញ្ញាប័ត្រសិក្សា មានប៉ុន្មានយ៉ាង? បុគ្គលិកក្រសួងសិក្សាធិការមានឈ្មោះអ្វីខ្លះ?

## វិធីអាន

## ផលល្អនៃសាលារៀន

សាលារៀនជាថ្លើមប្រមាត់របស់ប្រជាជាតិ ៗ ប្រទេសមិនអាចនឹងបង្ហូរទ្រព្យសម្បត្តិឲ្យប្រជារាស្ត្រគ្រប់រូបបាន ទាំងមិនអាចនឹងចែកការងារឲ្យកម្មករបានគ្រប់ ៗ គ្នាឡើយ ៗ ប៉ុន្តែអាចខំប្រឹងប្រែងផ្សាយបំណេះវិជ្ជាដល់កុលបុត្រទាំងឡាយបាន, បើប្រទេសនោះជាប្រទេសមានអារ្យធម៌ មានសាលារៀនគ្រប់គ្រាន់ ៗ

ហេតុដូច្នេះ គឺសាលារៀននេះឯងហើយដែលជាប្រភពផ្សាយបំណេះវិជ្ជា អាចញុំាងកុមារាកុមារីទាំងឡាយឲ្យចេះទាញយកប្រយោជន៍អំពីរូបកាយ អំពីគំនិតប្រាជ្ញា អំពីវិញ្ញាណរបស់ខ្លួន យកមកប្រើប្រាស់បាន ហើយនាំកុមារនោះឲ្យដល់ទៅគោលបំណងនៃវិជ្ជាជីវៈ ហាក់ដូចជាពោលថា ហៃបា, ឯងចូរដើរទៅចុះ! អាវុធមាននៅដៃឯងស្រាប់ហើយ ទោះបីយ៉ាងណាក៏ដោយ ឯងគង់

អាចនឹងតតាំងក្នុងការជីវៈបាន ។

សេចក្ដីសួរ :- ម្ដេចក៏ទុកសាលារៀនជាគ្រឿងប្រមាត់របស់ប្រជាជាតិ? ប្រទេសដែលប្រកបដោយអារ្យធម៌ តើពលរដ្ឋបេះធ្វើប្រទេសរបស់ខ្លួនឲ្យសម្បូរដោយអ្វីខ្លះ?

* * * *

## មេរៀនទី ១៧ អំពីគ្រូនិងសិស្ស



គ្រូត្រូវទូន្មានប្រៀនប្រដៅសិស្សឲ្យបានល្អ ជាអ្នកបំភ្លឺផ្លូវ ជា

អ្នកដឹកនាំដោយធ្វើខ្លួនឯងឲ្យជាគម្រូ បង្ហាញសិល្បសាស្ត្របំណេះវិជ្ជាដល់សិស្សមិនលាក់ទុក ។ល។

បំណាច់ខាងសិស្ស ត្រូវប្រតិបត្តិចំពោះគ្រូតាមនាទីរបស់ខ្លួន ដោយស្ថាន ៥ យ៉ាងគឺ :

១- ត្រូវធ្វើបដិគមនាការក្រោកឡើងទទួលគ្រូ គឺថាបើសិស្ស កំពុងអង្គុយនៅកន្លែងណាមួយ ដែលមិនមានបុគ្គលជាធំជាងគ្រូទេ ហើយបានឃើញគ្រូមកកាន់ទីនោះ ត្រូវក្រោកឈរឡើងដោយគោរព ។ បើលោកមានគ្រឿងបរិក្ខារ, ត្រូវទទួលយកអំពីលោក មកទុកដាក់តាមទីកន្លែងដោយអើពើ ត្រូវចាត់ចែងអាសនៈដើម្បីលោក; កាលបើលោកអង្គុយហើយ ទើបខ្លួនត្រូវអង្គុយ; កាលបើលោកក្រោកឈរខ្លួនទៅ ត្រូវក្រោកឈរគោរពគ្រូ ហើយត្រូវធ្វើអនុគមនាការជូនដំណើរលោក យ៉ាងជិតណាស់ត្រឹមមាត់ទ្វារក្រៅ ។

២- កាលបើគ្រូមានធុរៈរវល់, សិស្សត្រូវកុំធ្វើសោះអង្គើយព្រងើយកន្តើយឡើយ, ត្រូវដឹង, ត្រូវជួយ, ប្រសិនបើអាចធ្វើជួសបានក៏រឹងរឹតតែប្រសើរ; កាលបើគ្រូមានជម្ងឺ, សិស្សកុំគប្បីសំដែង

សេចក្ដីធុញទ្រាន់ ត្រូវថែទាំទ្រាំទ្រដោយអស់អញ្ញលំគេញចិត្តជាប ដល់គ្រូបានជាបរិភោគ; ដោយហោចទៅសូម្បីមាតាបិតាជាដើម របស់គ្រូមានជម្ងឺឈឺចាប់ ក៏គួរសិស្សចូលទៅជួយសម្រាលទុក្ខធុរៈ របស់គ្រូតាមការគួរដែរ ។ល។

៣ - សិស្សត្រូវជឿស្ដាប់ប្រតិបត្តិតាមឱវាទគ្រូ ដែលលោកទូន្មានដោយល្អ គឺថាបើលោកពោលប្រដៅចំពោះហេតុការណ៍ណាមួយហើយ, ត្រូវកំណត់ទុកឲ្យចាំជាក់ក្នុងចិត្ត ហើយពិចារណាមើលដោយល្អិតល្អ កាលបើយល់ឃើញត្រូវពិតប្រាកដហើយ គប្បីតាំងចិត្តឲ្យមានជំនឿយ៉ាងមាំហើយប្រតិបត្តិតាមភ្លាមកុំបង្អង់ ដើម្បីឲ្យគ្រូសប្បាយចិត្តគិតរកឧបាយពន្យល់ឲ្យខ្លួនបានល្អតទៅទៀត ។

ពិតដូច្នោះមែន ជំនឿនេះជាចេតសិកធម៌មួយយ៉ាងសំខាន់បំផុតរបស់មនុស្សក្នុងលោក កិច្ចការសារពើទាំងផ្លូវលោកទាំងផ្លូវធម៌ បើបុគ្គលអ្នកធ្វើ អ្នកប្រព្រឹត្ត គ្មានជំនឿមាំតាំងនៅក្នុងសន្ដានចិត្តទេ, នឹងមិនអាចសម្រេចបានឡើយ, ទោះបីបានសម្រេចក៏ពុំបានសមតាមបំណង; ព្រោះហេតុនោះយើងត្រូវជឿជាក់ចំពោះ

មាតាបិតាគ្រូអាចារ្យថា លោកដាស់តឿនក្រើនរំលឹកចង់ឲ្យបានល្អ ឲ្យបានសម្រេចប្រយោជន៍ពិត ៗ កាលបើយើងមានជំនឿជាក់ក្នុងចិត្ត ហើយ, វត្តប្រតិបត្តិនិងកិច្ចការរបស់យើងនឹងអាចប្រព្រឹត្តទៅបាន ដោយល្អប្រសើរពុំខាន, ហើយមាតាបិតាគ្រូអាចារ្យរបស់យើងក៏ នឹងពេញចិត្តគាប់អធ្យាស្រ័យចំពោះយើង ៗ ពាក្យនេះពិត, នរណាក៏ដោយ បើនិយាយប្រាប់ប្រដៅអ្នកដទៃ ដោយសុទ្ធចិត្តចង់ ឲ្យគេបានល្អ បានសម្រេចប្រយោជន៍ ហើយមិនឃើញគេយក ចិត្តទុកដាក់ប្រព្រឹត្តតាមទេ, រមែងអាក់អន់ស្រពន់ចិត្តគិតលែង និយាយស្តីថាតទៅទៀតពុំខាន ៗ

៤–សិស្សត្រូវយកចិត្តទុកដាក់បម្រើបម្រាស់គ្រូ ធ្វើវត្តប្រតិបត្តិ តូចធំ ៗ វេលាបម្រើបម្រាស់គ្រូ ត្រូវសំដែងទឹកមុខស្រស់ស្រាយ ហាក់ដូចជាសប្បាយចិត្តណាស់ដោយបានបំពេញធុរៈជូនលោកៗលៗ

៥ – សិល្បសាស្ត្របំណេះវិជ្ជា ដែលគ្រូបានដាក់ឲ្យរៀនឲ្យ ទន្ទេញ នោះត្រូវយកចិត្តទុកដាក់ស្វាធ្យាយទន្ទេញឲ្យពេញកម្លាំង ប្រាជ្ញាស្មារតីនៃខ្លួនដរាបដល់ចាំចូលចិត្ត ៗ ករណីយកិច្ចដែលគ្រូ

ដាក់ឲ្យធ្វើ នោះក៏ត្រូវខំប្រឹងធ្វើដោយល្អ ប្រាសចាកការខ្ជីខ្ជាធ្វើឲ្យរួចតែពីដៃ ៗ នៅពេលកំពុងសិក្សា ត្រូវកុំរើករើបែរមុខបែរក្រោយ និយាយកេះកៀវនឹងអ្នកជិតខាងឡើយ ត្រូវផ្ចង់ស្មារតីស្តាប់ពាក្យពន្យល់របស់គ្រូដោយសេចក្តីគោរព ។

គ្រូនិងសិស្ស បើបានប្រព្រឹត្តត្រឹមត្រូវតាមស្ថានដែលខ្លួនត្រូវអនុគ្រោះ ត្រូវប្រតិបត្តិទៅវិញទៅមក ដូច្នេះហើយ នោះឈ្មោះថាបានបិទបាំងភយន្តរាយមិនឲ្យកើតឡើង ឈ្មោះថាបានញ៉ាំងសេចក្តីសុខសម្រាន្តឲ្យបានកើតឡើងដល់ខ្លួន ៗ បើគ្រូ ឬសិស្សមិនប្រព្រឹត្តតាមបែបបទ ដែលខ្លួនត្រូវប្រព្រឹត្តទៅវិញទៅមកនោះទេ, នឹងមានទុក្ខភយន្តរាយកើតឡើងដល់ខ្លួនពិតប្រាកដ ។

ពណ៌នាមកនេះ ដោយឧបរិមបរិយាយ; បើនឹងនិយាយដោយហេដ្ឋិមបរិយាយ, លោកថា កុំបាច់និយាយដល់គ្រូអាចារ្យដែលបង្ហាត់បង្រៀនប្រដៅខ្លួនពិត ៗ សូម្បីតែលោកអ្នកណាដែលកំពុងទូន្មានប្រដៅសិស្ស ឬបង្ហាត់បង្ហាញគួរទៅឲ្យបានល្អត្រឹមត្រូវដោយនូវផ្លូវធម៌ ផ្លូវច្បាប់ ជាពាក្យមានសារប្រយោជន៍ គួររៀន

គួរស្តាប់, យើងបានឮពាក្យនោះចាំបានហើយយកមកត្រិះរិះប្រតិបត្តិតាមទៅកើតសេចក្តីសុខ-ចំរើន លោកអ្នកនោះក៏ឈ្មោះថា បុព្វការីរបស់យើងដែរ, យើងត្រូវដឹងគុណ ហើយតបគុណកុំភ្លេចឲ្យសោះ. យើងនឹងបានឈ្មោះថា កតញ្ញូ កតវេទី ។

សួរបាទ.- គ្រូត្រូវអនុគ្រោះសិស្សដូចម្តេចខ្លះ ? ចំណែកសិស្សត្រូវប្រតិបត្តិចំពោះគ្រូតាមនាទីរបស់ខ្លួនដោយស្លូតប៉ុន្មានយ៉ាង ? ពោលសំខាន់របស់សិស្សល្អដូចម្តេចខ្លះ ? សិស្សល្អគួរចៀសវាងទោសកំហុសព្រោះហេតុអ្វី ? ដូចម្តេចដែលហៅថាគំនិតល្អ ? ចូរពោលទោសកំហុសអ្វីខ្លះដែលអ្នកត្រូវចៀសវាង ព្រមទាំងពន្យល់ហេតុផលមកផង ។

* * * *

## មេរៀនទី ១៨ កិច្ចធុរៈផ្ទាល់ខ្លួនរបស់សិស្ស

## ការងារ, សេចក្តីព្យាយាម, ការស្តាប់បង្គាប់ដោយគោរព.

**Devoirs personnels de l'écolier**
**Travail, assiduité, docilité.**

១ – កូនសិស្សល្អជាអ្នកមានសេចក្តីព្យាយាមខ្ជាប់ខ្ជួន តែងទៅសាលាជានិច្ច រៀរលែងតែមានជម្ងឺឈឺនឹងកិច្ចការជាទម្ងន់ ៗ កូនសិស្សនេះមិនដែលខានទៅសាលាទេ ។ បើមានធុរៈ, តែងតែសុំច្បាប់

ត្រូវការពារខ្លួនជាដរាប ។

អធិប្បាយថា: មេរៀនមួយដែលបាត់ គឺដែលពុំបានរៀន នោះបណ្ដាលឲ្យខុសផ្លូវ ទាំងនាំឲ្យខាតពេលរៀនសារឡើងវិញៈច្រើន

សប្ដាហ: ។ ការងារដែលស្រួលបំផុតហើយនាំមកនូវប្រយោជន៍ គឺការងារដែលគេធ្វើឥតឈប់មិនឲ្យផ្អាកមិនឲ្យសល់ ។

គំនិតសេចក្ដីព្យាយាមប្រឹងប្រែង ត្រូវភ្ជាប់ ឬត្រូវបញ្ចូលសេចក្ដីទៀងទាត់មកទៀត, គឺជាដំណើរទៅដល់ឲ្យទាន់ពេលដែលកំរិត ។ ការទៀងទាត់ជាសណ្ដាប់ធ្នាប់មួយយ៉ាងល្អវិសេស ដែលគេត្រូវតែកាន់តាំងពីក្មេងទៅទល់គ្នានឹងស្លាប់ ។

២- កូនសិស្សល្អជាអ្នកស្ដាប់បង្គាប់ដោយចិត្តផង់, ជាអ្នកធ្វើការងារយ៉ាងល្អ, សប្បាយតែនឹងអប់រំវិជ្ជារបស់ខ្លួន, ធ្វើសតិរបស់ខ្លួនឲ្យរឹងប៉ឹង, ស្រេកឃ្លានតែក្នុងការរៀនសូត្រឲ្យបានចេះដឹងកើនឡើងរាល់ៗថ្ងៃ ។ សត្វកមរជាតិ (ឃ្មុំ) ឆ្លៀតក្នុងរដូវៈដើមឈើផ្កា ដើម្បីនឹងតុបតែងសំបុករបស់ខ្លួន (ផ្ទះឃ្មុំ) ។ សិស្សក៏ត្រូវឆ្លៀតពេលទាន់ខ្លួននៅជំទង់តូច ដើម្បីនឹងធ្វើគំនិតរបស់ខ្លួនឲ្យទៅជាមនុស្ស

មានប្រយោជន៍ក្នុងលោក ឲ្យដូចជាឃ្មុំដូច្នោះ, មិនត្រូវឲ្យខាតវេលាណាមួយទេ ខំធ្វើកិច្ចការងារដែលគ្រូដាក់ឲ្យធ្វើដោយយកចិត្តទុកដាក់, មិនចម្លងតាមគេ, មិនឲ្យអ្នកណាជួយ, ចេះជំនះក្នុងការងារដែលលំបាក, ដឹងថាត្រូវឲ្យនឿយហត់បន្តិច ទើបការងារនោះសម្រេចបាន; សមនឹងភាសិតបុរាណថា: "ចង់ឆ្ងាញ់ឲ្យរកអន្ទក់ ចង់ស្រណុកឲ្យនឿយមុន" ។

៣–កូនសិស្សល្អ តែងតែមានដួងចិត្តល្អ គឺជាអ្នកត្រងត្រាប់ស្តាប់បង្គាប់គ្រូជាដរាប មិនចេះឆ្លងឆ្លើយដោយពាក្យអាក្រក់ទៅកាន់គ្រូ, មិនតាំងខ្លួនឯងឲ្យជាអ្នកធ្វើចលាចល, ទាំងមិនធ្វើឲ្យមិត្រភក្តិកើតចលាចល ។

អធិប្បាយថា: នៅក្នុងកន្លែងរៀន កូនសិស្សល្អមិនធ្វើឲ្យមានសេចក្តីវឹកវរ ទាំងមិនធ្វើឲ្យមិត្រភក្តិគ្នាឯងមានសេចក្តីរំខានក្នុងករណីយកិច្ចដែលកំពុងធ្វើ, តែងក្រោកឈរជាដរាប កាលណាមានការសួរ, សាប់បង្គាប់ដោយរហ័សរហួន ។ ឃើញថានៅក្នុងសាលាកូនសិស្សល្អខំប្រឹងប្រែងរៀបចំខ្លួនឲ្យទៅជារបៀបល្អ ជាជាងដែល

នៅក្នុងគ្រួសាររបស់ខ្លួនទៅទៀត ។

៤ – យើងមិនត្រូវធ្វើខ្លួនឲ្យទៅជាកូនសិស្សខ្ជិល ដែលមិនយល់ក្នុងកសិកម្មរបស់មាតាបិតា, មិនធ្វើឲ្យខូចអនាគតរបស់ខ្លួន, មិនបំផ្លាញវេលាដែលត្រូវកសាងខ្លួន ដោយបិតនៅក្នុងការទំនេរឥតប្រយោជន៍ ។ សិស្សដែលមានកិរិយាមិនទៀងទាត់ មានការខុសពេលវេលា, នោះតែងទៅកាន់កន្លែងរៀនដោយយឺតយ៉ាវ ឬយកលេសគឺហេតុបន្តិចបន្តួចមកអាង តែងធ្វើឲ្យមានការវិកវរបលា-ចលដល់ការរៀន, ជាអ្នកតែងទទួលទណ្ឌកម្មជាញឹកញយ ធ្វើឲ្យមានសេចក្ដីលំបាកដល់គ្រូអាចារ្យនិងឪពុកម្ដាយ ។ ចំណែកឯកូនសិស្សល្អវិញ គេរាប់ថាជាសិស្សប្រសើរ ដែលអ្នកផងតែងស្រឡាញ់រាប់អានដោយគំនិតមារយាទល្អ ដោយការដែលវាធ្វើបានឲ្យផលល្អ, បានទៅជាអ្នកល្បីល្បាញមានកេរ្ដិ៍ឈ្មោះល្អក្នុងសាលារបស់ខ្លួន ។

## ភាសិត-បិណ្ឌ

សិស្សល្អតែងរៀបចំអនាគតរបស់ខ្លួនឲ្យជាទីសប្បាយ ។

បើអ្នកស្រឡាញ់ការរស់នៅ, អ្នកមិនត្រូវបំផ្លាញពេលវេលា ។

ការយកចិត្តទុកដាក់ប្រយ័ត្នចំនួនពីរបីម៉ោងក្នុងសាលា, ទុកជាថ្លៃ អត្តខាត់ដែលសំបៃដោយខ្សត់ខ្សោយក្នុងការរស់នៅ ។

គេនឹងចំទន់ទុកដូចជាដើមឈើ, •គេអាចនឹងដឹងអនាគតរបស់ ដើមឈើដោយសំគាល់ផ្លែជាដំបូង ។

មានតែការយកចិត្តទុកដាក់ប៉ុណ្ណោះទេ ដែលនឹងធ្វើឲ្យទៅជា មនុស្សថ្លៃថ្នូរ, មនុស្សក្លាហាន ឬវីរបុរសជាទេពកោសល ។

## ពាក្យពន្យល់

អត្តខាត់ គុ. ខ្សត់, ខ្សត់ខ្សោយ, ទ័លក្រ, ខ្សត់ទ្រព្យ ។

វីរបុរស ន. បុរសមានព្យាយាម (អ្នកប្រាជ្ញ) ។

ទេពកោសល ន. មនុស្សឈ្លាសវៃដូចជាទេវតា

សេចក្ដីសួរ.. សិស្សត្រូវព្យាយាមដូចម្ដេចខ្លះ? មេរៀនអ្វីៗដែលរំលងពុំបាន រៀន ទុកដូចជាអ្វី? ការងារដែលស្រួលហើយនាំមកនូវប្រយោជន៍ តើការងារអ្វីៗ ចូរ លើកឧទាហរណ៍ណាមួយមកប្រៀបប្រដូចនឹងសិស្សដែលខំប្រឹងប្រែងរៀនសូត្រ! សិស្ស ល្អ នៅទីកន្លែងរៀនរកធ្វើដូចម្ដេចខ្លះ? កូនសិស្សខ្ជិលនឹងធ្វើខ្លួនទៅអនាគតដូចម្ដេច?

សិស្សល្អនឹងរៀបចំខ្លួនទៅអនាគតដូចម្ដេចខ្លះ? ចូរលើកភាសិត-បំផ្លាខ្លះក្នុងករណីយ-កិច្ចរបស់សិស្ស !

# ការអាន

បើគេមិនទម្លាប់រៀនធ្វើការនៅសាលាទេ, គេនឹងទៅជាមនុស្សខ្ជិលអស់មួយជីវិត ហើយនឹងទៅជាមនុស្សឥតប្រយោជន៍ ។

តើអ្នកនឹងយល់ដូចម្ដេច សត្វបក្សីដែលមានស្លាបមិនព្រមហើរ; ត្រីពុំព្រមហែល; សត្វឈ្លូសដេកព្រាលតែនឹងកន្លែង ពុំរបាលទៅតាមក្ដីសប្បាយ; គ្រាប់ស្វាយពុំព្រមដុះពន្លកឲ្យទៅជាដើមស្វាយធំ ស៊ូស្អុយរលួយក្នុងកក់ផុង; ស៊ុតមាន់ពុំព្រមញាស់ចេញពីសំបុក ?

អ្នកមុខជានឹងពោលថា គឺជាសត្វ ជាវត្ថុ ដែលពុំបានបំពេញករណីយកិច្ចរបស់ខ្លួនដែលកើតមកលើផែនដី ។ ខុសនឹងច្បាប់សាស្ដា ។ អើសំឡាញ់, នេះហៅថាខ្ជិល, ខ្លួនឯងដូចជាសត្វឬវត្ថុដែលពុំសមរំនោះដែរ ។

តើអ្នកយល់ដូចម្ដេច កង្ហារកិនស្រូវចេះតែវិលទៅតាមខ្យល់

ឥតស្រូវ ១ គ្រាប់គិនសោះ បានតែឮស្សូរឥតអំពើរ; មនុស្សនៅ

កណ្ដាលសាគរ ពុំព្រមចូលវៃវ ពុំព្រមទៅឲ្យដល់ត្រើយ ចង់តែ

លិចទៅកន្ទឹក ៗ ដូច្នេះមនុស្សឈប់ធ្វើការគឺឈប់វៃវ ៗ

## ការដាក់ឲ្យធ្វើ

មនុស្សមិនទម្លាប់ហាត់រៀននៅសាលា តើដល់ខ្លួនធំឡើងនឹង

ទៅជាដូចម្ដេច ?

ចូរអធិប្បាយដំនៃរឿងត្រង់ពាក្យថា ឈប់ធ្វើការគឺឈប់វៃវ ៗ

* * * *

## មេរៀនទី ១៩ ករណីយកិច្ចទៅវិញទៅមក បំពោះមិត្តសំឡាញ់

## Devoirs réciproques des camarades

១–សាលារៀនទុកដូចជាគ្រួសារបន្ទាប់មួយ ៗ ក្មេងទាំង-

ឡាយទៅមកកាន់សាលារៀន ឲ្យនៅជាមួយគ្នាអស់ខែឆ្នាំដំយូរ, វា

បានទទួលការបង្ហាត់បង្រៀនពីគ្រូជាមួយគ្នា, បានធ្វើការឲ្យលេងជា

មួយគ្នា, បើទុកណាមិនមែនជាបងប្អូនបង្កើត ដែលកើតមកពីឈាម

ជាមួយគ្នាក៏ដោយ ក៏ត្រូវតែប្រព្រឹត្តឲ្យជាមិត្តភក្តិល្អនឹងគ្នា ឲ្យសមនឹងភាសិតបុរាណថា "នៅផ្ទះម្ដាយទីទៃ ទៅព្រៃម្ដាយជាមួយ" ។

២ មិត្តភក្តិល្អ ត្រូវតែសំដែងបាតុកម្មយ៉ាងល្អ ចំពោះគ្នានឹងគ្នា ។ គួកនល្អចេះធ្វើឲ្យមិត្តភក្តិស្រឡាញ់រាប់អាន ។

អធិប្បាយថា: សិស្សល្អមិនមានការឥច្ឆា (ប្រណែន) កំណាញ់ ចេះចែករំលែកវត្ថុទាំងពួងដល់មិត្តភក្តិរបស់វា, មិនមានអាការៈឃោរឃៅនឹងគោងកាច, ជួយការពារមិត្តភក្តិដែលខ្សោយ ហើយចេះទទួលដោយមិត្តភាពចំពោះសិស្សដែលមកដល់ថ្មី ដែលតែងមានសេចក្ដីអើលកើតភ័យអៀនខ្មាស ដោយឃ្លាតចេញពីគ្រួសារខ្លួន ។ សិស្សល្អមិនរិះគន់តិះដៀលដល់មិត្តភក្តិណា ដែលមានអវយវៈវិកលវិការ ឬមានសំលៀកបំពាក់មិនសមរម្យ ។ វាមិនមានសេចក្ដីគុំគួនទាំងមិនមានឈ្នានីសប្រណែនទិន្នាឡើយ; វាមិនសេពគប់នឹងមិត្តភក្តិអាក្រក់ មិនធ្វើយទម្លាក់ដាក់ទោសទៅលើគេ; បើមាននរណាប្រព្រឹត្តអាក្រក់, វាតែងតែជួយដាស់តឿនឲ្យបានល្អ ។

៣–នៅសាលារៀន គេត្រូវបំពេញគុណធម៌ដែលគេត្រូវយក

ទៅប្រើប្រាស់ក្នុងសមាគម ។ ក្មេងទាំងឡាយត្រូវហាត់ធ្វើចរិយាឲ្យល្អដល់គ្នានឹងគ្នា ឲ្យដូចជាមនុស្សចាស់ដែរ ។

អធិប្បាយថា: អ្នកមានគូកនល្អ នឹងមានភ័ព្វព្រេងវាសនាទៅជាមនុស្សថ្លៃថ្នូរត្រឹមត្រូវ នឹងទៅជាពលរដ្ឋដ៏ប្រសើរ ។ យើងត្រូវធ្វើឲ្យគេស្រឡាញ់រាប់អាន ដោយការសុចរិតរបស់យើង, ដោយចិត្តល្អ, ដោយការរាប់រក នឹងការខ្នះខ្នែងរបស់យើង ។ យើងត្រូវជំនះនឹងទម្លាប់អាក្រក់ ហើយត្រូវធ្វើទម្លាប់ល្អទុកជាគំរូ ។ យើងត្រូវប្រព្រឹត្តនឹងគូកនយើងឲ្យទៅជាមិត្តភក្តិដ៏ភក្ដី ។

## ភាសិត-បិត្តា

សាលារៀនជាគ្រួសារមួយដែលក្មេងទាំងឡាយ ត្រូវរាប់អានដូចជាបងប្អូនបង្កើត ។

អ្នកណាឲ្យដំបូន្មានមួយល្អ ប្រសើរជាជាងឲ្យមាសមួយដុំ ។

ទឹកក្រខ្វក់មួយស្លាបព្រា អាចនឹងធ្វើទឹកមួយក្អម ឬជាត្រីស្អុយមួយ អាចនឹងធ្វើត្រីមួយត្រក ឲ្យស្អុយផង ។

គូកន ជាបក្ខពួកដំបូងរបស់មេត្រីភាព ។

## ពន្យល់ពាក្យ

**ដំបូន្មាន** ន. សេចក្ដីទូន្មាន, ឱវាទ, ឲ្យដំបូន្មាន, ស្ដាប់ដំបូន្មាន ។

**មេត្រីភាព** ន. សេចក្ដីរាប់រក, សេចក្ដីរាប់អានដោយប្រណី ។

ចោទសួរ.. ព្រោះហេតុអ្វីបានជាសាលារៀនទុកដូចជាគ្រួសារបន្ទាប់, ចូរឆ្លើយព្រមទាំងពន្យល់ហេតុផលមកផង? សិស្សត្រូវប្រព្រឹត្តនឹងគ្នាទៅវិញទៅមកដូចម្ដេចខ្លះ? ចូរអធិប្បាយពីពាក្យថា ទុកជាប័ក្ខពួកដ៏ល្អរបស់មេត្រីភាព ។

* * * *

## មេរៀនទី ២០ ការចេញចាកសាលា

### après l'école

១ – ការសិក្សារបស់សិស្ស ដែលចាកចេញពីសាលាទៅ ពុំទាន់ចប់សព្វគ្រប់ទេ ក្នុងអាយុ ១២ ឬ ១៥ ឆ្នាំ ។ វាតែងស្វែងទៅរកបំពេញវិជ្ជារបស់វាថែមទៀត ។

អធិប្បាយថា: សិក្ខាកាមកុលបុត្រដែលចេញពីសាលាទៅ ហើយ ត្រូវទៅបំពេញវិជ្ជានៅទីដែលមានគេបង្រៀនពួកជនជំទង់ នៅក្នុងភូមិខ្លួន ឬចូលទៅក្នុងមណ្ឌលរៀនដែលមានគ្រូយ៉ាងចំណាន